ធម៌នមស្សការ

អក្សរបាលី និង សំរាយ

សង្ខេប

ព.ស ២៥៥៦

គ.ស ២០១២

សំរាប់ជាធម្មទាន

ជាធម្មទាន

របស់

3

ឧបាសិកា **ឡុង ឈុន** *ព្រមទាំងបុត្រ និង ចៅ*

សូមឧទ្ទិសជូន

ចំពោះវិញ្ញាណខន្ធ

ឧបាសក **អ៊ាន មុយ**

ព្រមទាំងញាតិទាំងឡាយក្នុងសង្សារវដ្តនេះ

សូមអោយបានដល់នូវ សេចក្តីសុខ និង

បរមសុខ គឺ ព្រះនិព្វានគ្រប់ៗគ្នា ។

អារម្ភកថា

🕯🕯🕯🕯🕯 ☸ 🕯🕯🕯🕯🕯

សៀវភៅ **ធម៌នមស្សការ អក្សរបាលី និង សំរាយសង្ខេប** នេះ រៀបរៀងឡើងសំរាប់បំពេញនូវ សេចក្តីត្រូវការរបស់ពុទ្ធបរស័ទដែលមានបំណងចង់រៀនសូត្រព្រះធម៌ ។ ពុទ្ធបរស័ទមួយចំនួនមិនសូវចេះអាន អក្សរបាលី ដែលនាំអោយមានការពិបាក ក្នុងការ ចងចាំនូវពាក្យពេចន៍សូត្រធម៌នេះ ។ ហេតុដូច្នេះ ខ្ញុំក៏ សំរេចចងក្រងសៀវភៅនេះឡើងដោយបានដកស្រង់ចេញពីសៀវភៅ **ធម៌នមស្សការ អក្សរបាលី និង សំរាយសង្ខេប** របស់ព្រះតេជគុណ ***យ៉ាន យាន*** (ព.ស ២៥៥២) ។

ខ្ញុំសង្ឃឹមថាសៀវភៅធម៌នមស្សការ អក្សរបាលី និងសំរាយសង្ខេបនេះ នឹងបានជាប្រយោជន៍ដល់ពុទ្ធបរស័ទទាំងអស់ក្នុងការស្វែងយល់រៀនសូត្រ អំពីព្រះធម៌ ដើម្បីជំរុញអោយ ព្រះពុទ្ធសាសនាកាន់តែមានភាពរីកចំរើន និង គង់វង្សគ្រប់ ៥,០០០ព្រះវស្សា ។

ឧបាសិកា ឡុង ឈុន

មាតិកាធម៌

ឈ្មោះ **លេខទំព័រ**

បទសរភញ្ញ និង នមស្សការ ១
បទសូត្រលើកទង់ព្រះពុទ្ធសាសនា ២
ប្រវត្តិនៃទង់ព្រះពុទ្ធសាសនា ៤
កំណើតឆព្វណ្ណរង្សី..៦
ធម៌ថ្វាយបង្គំព្រះប្រាំព្រះអង្គ.. ៩
រតនបូជា ១០
ត្រៃរតនប្បណាម ១១
ធម្មរតនប្បណាម ១៥
សង្ឃរតនប្បណាម ២០
យោកប្បកោដី ២៥
ថ្វាយបង្គំសុំសេចក្ដីសុខ ២៧
នមស្ការបូជនីយវត្ថុជាទីគោរព ២៩
ពុទ្ធបាទនមស្សការគាថា ៣០
បាលីយកវត្តព្រះ ៣៣
វិធីសមាទាសីល ៥ (និច្ចសីល) ៣៥
វិធីសមាទានសីល ៨ ឧបោសថ ៤១
សមាទានសីល ១០ ....៤៧

របៀបអ្នករក្សាសីល ១០ .... ៥៤
អង្គនៃនិច្ចសីល ៥៦
អានិសង្សរបស់សីល ៥៩
ធម៌សូត្រសុំសេចក្ដីសុខ ៦១
បត្តិទានគាថា ៦៤
ធម៌សម្រាប់សូត្រឧទ្ទិស ៦៨
តេជៈខ្ញុំសាង ៦៩
អនុស្សតិ ១០ យ៉ាង ៧០
ធម៌សម្រាប់ច្រូចទឹកស្នោទក់.. ៧១
ខមាបនគាថា ៧៥
បត្តិទានគាថា ៧៦
យំកិញ្ចិប្រែជាពាក្យកាព្យ.. ៧៩
ធម៌ឧទ្ទិសផល ៨០
ផ្សាយមេត្តាចំពោះទិសទាំង ១០ .... ៨២
សុភមង្គលកថា ៨៥
បារមីធម៌ ៣០ យ៉ាង ៨៦
កុសលកម្មបថ ១០ យ៉ាង ៩០
អកុសលកម្មបថ ១០ យ៉ាង ៩២

ឥរិយាបថថ្វាយបង្គំព្រះរតនត្រ័យ

(សំរាប់ឧបាសក)



ឥរិយាបថទី១

ឥរិយាបថទី២

ឥរិយាបថទី៣

ឥរិយាបថទី៤

(សំពះឧបាសិកា)

ឥរិយាបថទី១

ឥរិយាបថទី២

ឥរិយាបថទី៣



ឥរិយាបថទី៤

បទសរភញ្ញ និង នមស្សការ

✡✡✡ 📖 ✡✡✡

សូមថ្វាយបង្គំព្រះសម្ពុទ្ធ   ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្ដា   ទ្រង់ត្រាស់ទេសនាប្រដៅសត្វ។
ចង្អុលឲ្យដើរផ្លូវកណ្ដាល   មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់   អាចកាត់សង្សារៈទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ   សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន   កាន់តាមលំអានបានក្ដីសុខ ។
ឥតមានសុខណាស្មើក្ដីស្ងប់   បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ   ក្ដីសុខនឹងមានព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌   ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរត្ន័គួរគោរព   ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ   វិសុទ្ធតាមអង្គព្រះសាស្ដា
សូមគុណត្រៃរ័ត្នជួយខេមរា   ឲ្យបានសុខាតរៀងទៅ ។

(សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ)

បទស្ងួត្រលើកទង់ព្រះពុទ្ធសាសនា

✡✡✡ 📖 ✡✡✡

១. សូមមើលទង់ជ័យ ឆព្វណ្ណរង្សី
ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស
ហង្សបាទនិងពណ៌ ជ័ភ្លឺផ្លេក ។

២. ប្រទេសតូចធំ បានស្ម័គ្រស្មោគមន៍
ជំនុំគ្នាច្រើន អនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក
ប្រសើរពន់ពេក ក្រៃកន្លង ។

៣. ធ្វើជាសញ្ញា ទង់ជ័យសាសនា
នៃសម្ពុទ្ធធំចម្បង ចូរយើងរាល់គ្នា
យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។

៤. ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា
សុទ្ធសឹងតែជា ពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់
ប្រឹងប្រែងឲ្យណាស់ គ្រប់ៗគ្នា ។

៥. សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត
រុងរឿងវិសុទ្ធ ថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា
ដោយជនជ្រះថ្លា ច្រើនសែនលាន ។

៦. មានចិត្តស្នេហា គោរពបូជា
ចំពោះព្រះធម៌ ដ៏កល្យាណ
ទាំងមនុស្សទេវ្តា ស្នេហាគ្រប់ប្រាណ
ប្រាថ្នាចង់បាន សេចក្តីសុខ ។

៧. យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត
កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ
យើងនឹងបានសុខ ក្សេមក្សាន្តត្រាណ ។

៨. ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត
ឆ្ពោះទៅកាន់ឋាន និព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត
ជាតិយើងនឹងបាន សោយសុខា ។

ប្រវត្តិនៃទង់ព្រះពុទ្ធសាសនា

✡✡✡ 🕮 ✡✡✡

ការបរិនិព្វាន នៃព្រះអរហន្តសម្មាសម្ពុទ្ធ កន្លងផុតទៅ ២៤៩៣ ឆ្នាំ មិនទាន់មានប្រទេសពុទ្ធសាសនិកណាមួយ បាន បង្កើតនូវទង់ពុទ្ធសាសនាឲ្យមានរូបរាងពិតប្រាកដនៅឡើយ ។

ទើបតែថ្ងៃអង្គារ ៦ រោច ខែជេស្ឋ ឆ្នាំខាល ទោស័ក ព.ស ២៤៩៣ ត្រូវនឹងថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ១៩៥០ ពុទ្ធិក ២៩ប្រទេស មានប្រទេសស្រីលង្កា ជាដើម បានបង្កើតពុទ្ធិកសមាគមពិភព លោក ធ្វើសន្និសីទលើកទី១ នៅប្រទេសស្រីលង្កា។ គណៈប្រតិភូ ខ្មែរមានសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត ជោតញ្ញា-ណោ** ជាប្រធានទៅចូលរួមប្រជុំផង បានមូលមតិគ្នាបង្កើតជា ទង់សាសនាឡើង ។ ទង់នេះរួមមាន ៦ពណ៌ ដើម្បីតម្រូវនឹង ឆព្វណ្ណ-រង្សី នៃព្រះសម្ពុទ្ធទាំង ៦ ពណ៌ គឺ ខៀវ លឿង ក្រហម ស ហង្សបាទ និង ផ្លេក ។

១. រស្មីពណ៌ខៀវ តំណាងព្រះអង្គ កាលសោយព្រះជាតិ ជាព្រះបាទស្រីភិរាស្ត្រ ។ កាលនោះព្រះឥន្ទ បាននិម្មិតខ្លួនជា ព្រាហ្មណ៍ចាស់ម្នាក់ ចូលមកសុំព្រះនេត្រព្រះអង្គទាំងគូ ព្រះអង្គ

ទ្រង់ឆ្កៀលព្រះនេត្រទាំងគូឲ្យទៅឥន្ទព្រាហ្មណ៍ ។

២. រស្មីពណ៌លឿង តំណាងព្រះអង្គកាលទ្រង់សោយព្រះជាតិជា វិរិយបណ្ឌិត ។ កាលនោះ ព្រះឥន្ទបាននិម្មិតខ្លួនជាយក្សធ្វើជាងមាស វិរិយបណ្ឌិតបានអារសាច់ខ្លួន ឲ្យជាងមាសផែធ្វើជាមាសបិទព្រះពុទ្ធរូប ។

៣. រស្មីពណ៌ក្រហម តំណាងព្រះអង្គកាលសោយព្រះជាតិជាបទុមមាណព។ គ្រានោះមានពស់មួយប្រកបដោយពិសដ៏ពន្លឹកបាន ចឹកមាតាព្រះអង្គៗ បានយកកាបិតពុះទ្រូងយកបេះដូងផ្សំថ្នាំព្យាបាលមាតាឲ្យជាសះស្បើយ ។

៤. រស្មីពណ៌ស តំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ បានប្រទានដំរីមង្គលមួយដែលមានអវយវៈសសុទ្ធជារបស់សម្រាប់រាជ្យដល់ពួកព្រាហ្មណ៍កលិង្គរដ្ឋ ពួកអ្នកនគរខឹងក៏បំបរបង់ព្រះអង្គឲ្យទៅនៅភ្នំវង្កត់ ។

៥. រស្មីពណ៌ហង្សបាទ តំណាងព្រះអង្គកាលទ្រង់សោយព្រះជាតិជា វិជ្ជាធរ យក្សចាប់មាតាព្រះអង្គៗបានអារសាច់ឲ្យយក្សបរិភោគ ជំនួសជីវិតមាតា ។

៦. រស្មីពណ៌ផ្លេក តំណាងព្រះអង្គកាលសោយព្រះជាតិ

ជាទន្សាយឈ្មោះ សោមបណ្ឌិត មានសទ្ធាចង់បំពេញទាន ពេលនោះ ព្រះឥន្ទបាននិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ អត់អាហារ ដើរចូលមកទន្សាយ សោមបណ្ឌិត បានលោតចូលភ្នក់ភ្លើង ដើម្បីចម្អិនសាច់ព្រះអង្គឲ្យដល់ឥន្ទព្រាហ្មណ៍បរិភោគ ។

កំណើតឆព្វណ្ណរង្សី

១. ជាតិយើង អ្នកកាន់សាសនា
ត្រូវដឹងច្បាស់ថា ព្រះដ៏មានព្រះភាគ
ព្រះពុទ្ធជិនស្រី ទ្រង់មានឆព្វណ្ណរង្សី
គឺព្រះរស្មី ទាំងប្រាំមួយពណ៌ ។

២. ផ្សាយចេញ ពីព្រះកាយទ្រង់
រុងរឿងឫទ្ធិរុង ប្រសើរបវរ
ឆ្វៀលឆ្វាត់ កាយឆើតឆាយល្អ
ទាំងប្រាំមួយពណ៌ ស្រស់ល្អសោភា ។

៣. កំណើត នៃព្រះរស្មី
កើតដោយបារមី នៃព្រះភគវា
ធ្វើទាន ឥតមានរុញរា
កាលដែលនៅជា ព្រះពោធិសត្វ ។

៤. រស្មី ពណ៌ខៀវនោះណា
កាលភ្លៀលនេត្រា ទ្រង់ដោយចិត្តកាត់
ធ្វើទាន ដល់ឥន្ទព្រាហ្មណ៍ពិត
កាលនៅជាក្សត្រ នាមស្រីពិរាស្ត្រ ។

៥. រស្មី ពណ៌លឿងនោះណា
កាលដែលទ្រង់អាវ សាច់ផែធ្វើមាស
បិទពុទ្ធរូប ភ្លឺល្អឱភាស
ព្រះឥន្ទជាងមាស ទ្រង់រៃបណ្ដិត ។

៦. រស្មី ក្រហមនោះណា
កាលដែលមាតា ពស់ខាំស្លាប់ពិត
បទុម ស៊ូប្ដូរជីវិត
កាត់បេះដូងបិទ ធ្វើថ្នាំមាតា ។

៧. រស្មី ពណ៌សសុទ្ធសាធ
កាលដែលព្រះបាទ វេស្សន្តរក្សត្រា
ឲ្យទាន ដំរីសសោភា
ដែលព្រាហ្មណ៍ប្រាថ្នា យកពោធិញ្ញាណ ។

៨. រស្មី ពណ៌ដូចជើងហង្ស
កាលមាតាទ្រង់ យក្ខចាប់យកបាន

វិជ្ជាធរ	អោរសាច់ខ្លួនប្រាណ
យក្ខសាមាន្យ	ស៊ូប្តូរជីវិត ។
៩. រស្មី	ភ្លឺផ្លេកពណ្ណរាយ
កាលជាទន្សាយ	ឈ្មោះសោមបណ្ឌិត
ឲ្យទាន	សាច់ឈាមជីវិត
ដល់ឥន្ទព្រាហ្មណ៍ពិត	ថាអត់អាហារ ។
១០. រស្មី	ខៀវលឿងក្រហម
សហាង្សប្រាទព្រម	ភ្លឺផ្លេករស្វារ្យ
ត្រូវជា	ប្រាំមួយប្រការ
ក្មេងចាស់កុមារ	ចូរចាំទុកអើយ ។

ធម៌ថ្វាយបង្គំព្រះប្រាំព្រះអង្គ

ឧកាសខ្ញុំសូមវន្ទា នូវព្រះឈ្នះមារ ទាំងប្រាំព្រះអង្គ
សូមយាងព្រះបារមី ម្ចាស់ថ្លៃមកគង់ នៅនាកំឡុង ។
ទីស្ថាននេះណា ព្រះកុកសន្ធោ ព្រះកោនាគមនោ
ព្រះកស្សបោ ព្រះសមណគោតម បរមពុទ្ធោ ។
ព្រះមេតេយ្យោ ព្រះពោធិសត្វថ្លៃ ព្រមទាំងព្រះធម៌
ផ្សាលជ្រៅបវរ ប្រសើរពេកក្រៃ ប្រាំបីម៉ឺនបួនពាន់។
ព្រះធម្មក្ខន្ធនេះនៃ របស់ព្រះជិនស្រី ទីទៃរាល់អង្គ
ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្រព្រះពុទ្ធ ។
លះកាត់តណ្ហា ប្រសើរបំផុត ខ្ញុំសូមលំអុត
កាយវាចាចិត្ត ដោយតេជះខ្ញុំ លើកហត្ថបង្គំ ។
ត្រៃរតនា សូមកំចាត់បង់ សត្រូវនានា
ទុក្ខសោករោគា វិនាសទៅហោង ។

រតនបូជា

✡✡✡ 🕮 ✡✡✡

ឥមេហិ ទីបធូបាទិ សក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ

(អ៊ិម៉េហិ ទីប៉ាក់ធូប៉ាទិ សាក់ការេហិ ពុទ្ធធាំង ធ័មមាំង សាំងឃាំង)

អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច

(អាក់ភិប៉ូជាក់យាមិ មាតាប៉ិតាទីណាំង គុណាក់វ៉ាន់តាណាញ់ចាក់)

មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

(ម៉ៃហាញ់ចាក់ ទីឃាក់រ៉ាត់តាំង អាត់ថាយក្ស ហិតាយក្ស សុខាយក្ស)

<u>ប្រែថា:</u> *ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានទៀន និងធូប ជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយមាន មាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។*

នមោ តស្ស ភគវតោ អរហតោ

(នាក់មោ តាស់សាក់ ភាក់គាក់វ៉ាក់តោ អាក់រ៉ាក់ហាក់តោ)

សម្មាសម្ពុទ្ធស្ស ។ *(សាំម៉ាសាំពុទ្ធធាស់សាក់) (សូត្របីចប់)*

<u>ប្រែថា:</u> *វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវ ញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ ។*

ត្រៃរតនប្បណាម

✡✡✡ 📖 ✡✡✡

ព្រមទាំងបូជាគ្រឿងសក្ការៈ

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ

(យោ សន់និសិនណោ វាក់រាក់ពោធិមូលេ មារ៉ាំង សាក់សេណាំង)

មហតឹ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញាណោ

(មាក់ហាក់តឹង វិជៃយោ សាំពោធិមាគាច់ឆិ អាក់នន់តាក់ញាណោ)

លោកុត្តមោ តំ បនមាមិ ពុទ្ធំ

(លោកកុតតាក់ម៉ោ តាំង ប៉ាក់នាក់ម៉ាមិ ពុទធាំង)

<u>ប្រែថា:</u> *ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្ស ដ៏ប្រ-*

សើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើនហើយទ្រង់ត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មានព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា

(យេ ចាក់ ពុទធា អាក់តីតា ចាក់ យេ ចាក់ ពុទធា អាក់ណាគាក់តា)

បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ ពុទធា អាក់ហាំង វ៉ាន់ទាមិ សាប់ពាក់ទា)

__ប្រែថា:__ ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណាដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកល្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ ព្រះសម្មាសម្ពុទ្ធ ទាំងឡាយនោះគ្រប់កាលទាំងពួង ។

ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ

(អ៊ិតិប៉ិសោ ភាក់គាក់វ៉ា អាក់រ៉ាក់ហាំង សាំម៉ាសាំពុទ្ធោ)

វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ

(វិជ្ជាចាក់រ៉ាក់ណាក់សាំប៉ាន់ណោ សុគាក់តោ លោកាក់វិទូ)

អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវ

(អាក់នុតតាក់រ៉ោ ប៉ុរិសាក់ទាំមាក់សារាក់ថិ សាត់ថាទេវាក់)

មនុស្សានំ ពុទ្ធោ ភគវាតិ ។

(មាក់នុសសាណាំង ពុទ្ធោ ភាក់គាក់វាតិ)

<u>**ប្រែថា:**</u> **ឥតិបិសោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺ កិលេសព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។* **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា៣ និង វិជ្ជា៨ និង ចរណៈ១៥* **សុគតោ** *ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរ-ស្ថាន គឺអមតៈមហានិព្វាន* **លោកវិទូ** *ទ្រង់ព្រះនាមថាលោកវិទូ ព្រោះ ព្រះអង្គទ្រង់ជ្រាបច្បាស់ នូវត្រៃលោក* **អនុត្តរោ** *ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន* **បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថាបុរិស-*

ទម្មសារថិ ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមានឧប-និស្ស័យគួរនឹងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថាពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញ៉ាំង ពុទធោ)

មេ សរណំ វរំ ឯតេន សច្ចវជ្ជេន

(មេ សាក់រាក់ណាំង វាក់រ៉ាំង អេតេនាក់សាច់ចាក់វាច់ជេនាក់)

ហោតុ មេ ជយមង្គលំ ។

(ហោតុ មេ ជាក់យក្សម៉ាំងគាក់លាំង)

<u>**ប្រែថា:**</u> **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធ ជាម្ចាស់ជាទីពឹង ទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរ មានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(រួចហើយត្រូវសូមខមាទោសនឹងព្រះពុទ្ធគុណដូច្នេះថា)

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ

(អ៊ុតតាក់មាំងគេនាក់ វាន់ទេហាំង ប៉ាទាក់ប៉ុងស៊ុង
វាក់រុតតាក់មាំងពុទធេ)

យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ

(យោ ខាក់លិតោ ទោសោ ពុទធោ ខាក់មាក់តុ តាំង មាក់មាំង)

<u>ប្រែថា:</u> ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ដោយ អវយវៈដ៏ឧត្តមគឺ ត្បូង* **ពុទ្ធេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់* **ពុទ្ធោ ខមតុ តំ មមំ** *សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

(ក្រាបថ្វាយបង្គំម្តង)

ធម្មរតនប្បណាម

✡✡✡ 📖 ✡✡✡

អដ្ឋង្គិការីយបថោ ជនានំ មោក្ខប្បវេសាយ

(អាត់ថាំងគិការីយក្បប៉ាក់ថោ ជាក់នាណាំង
មោកខាប់ប៉ាក់វេសាយក្ប)

ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ

(អ៊ុជូ ចាក់ មាគ់គោ ធ័មមោ អាក់យ៉ាំង សន់តិកាក់រ៉ោ)

បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ

(ប៉ាក់ណីតោ និយានិកោ តាំង ប៉ាក់នាក់ម៉ាមិ ធ័មមាំង)

ប្រែថា: ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ៨ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញុំាងសត្វឲ្យចេញចាក សង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា

(យេ ចាក់ ធ័មមា អាក់តីតា ចាក់ យេ ចាក់ ធ័មមា អាក់ណាគាក់តា)

បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ ធ័មមា អាក់ហាំង វាន់ទាមិ សាប់ពាក់ទា)

<u>ប្រែថា:</u> ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មា-សម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះ សម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ

(ស្វាកខាតោ ភាក់គាក់វាក់តា ធ័មមោ សន់ទិដថិកោ)

អកាលិកោ ឯហិបស្សិកោ ឱបនយិកោ

(អាក់កាឡិកោ អេហិប៉ាស់សិកោ អោប៉ាក់នាក់យិកោ)

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

(ប៉ាច់ចាត់តាំង វេទិតាប់ពោ វិញ្ញូហីតិ)

<u>ប្រែថា:</u> ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ (ធម្មោព្រះនព្វលោកុត្តរធម៌មាន៩ប្រការគឺមគ្គ ៤ ផល ៤ និព្វាន ១) **សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញ ពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់

ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានឃើតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបានសំរេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបន-យិកោ** ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

(ក្រាបថ្វាយបង្គំម្តង)

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញ៉ាំង ធ័មមោ មេសាក់រ៉ាក់ណាំង វាក់រ៉ាំង)

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

(អេតេនាក់ សាច់ចាក់វាច់ជេនាក់ ហោតុ មេ ជាក់យក្សមាំងគាក់លាំង)

<u>**ប្រែថា:**</u> **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ច-**

ឥទ្ធៀន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គលចូរមាន ដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចនេះ ។

(ក្រាបថ្វាយបង្គំម្តង)

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ

(អ៊ុតតាក់ម៉ាំងគេនាក់ វ៉ាន់ទេហាំង ធ័មម៉ាញ់ចាក់

ទុវិធាំង វ៉ាក់រ៉ាំង)

ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុតំ មមំ

(ធ័មមេ យោ ខាក់លិតោ ទោសា ធ័មមោ

ខាក់មាក់តុតាំង មាក់ម៉ាំង)

<u>ប្រែថា:</u> **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺ ព្រះបរិយត្តិ-ធម៌ និង ព្រះនព្វលោកុត្តរធម៌ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ-យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុតំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

សង្ឃរតនប្បណាម

✡✡✡ 🕮 ✡✡✡

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ

(សាំងឃោ វិសុទធោ វាក់រាក់ទាកខិណៃយ៉ោ សន់តិនទ្រិយោ)

សព្វមលប្បហីនោ គុណេហិ នេកេហិ សមិទ្ធិបត្តោ

(សាប់ពាក់មាក់លាប់ប៉ាក់ហីណោ គុណេហិ នេកេហិ សាក់មិទធិប៉ាត់តោ)

អនាសវោ តំ បនមាមិ សង្ឃំ

(អាក់ណាសាក់វ៉ោ តាំង ប៉ាក់នាក់ម៉ាមិ សាំងឃាំង)

<u>ប្រែថា:</u> *ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេសជា ទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយស្ងប់ហើយមានមន្ទិលគឺ រាគាទិក្កិលេស ទាំងពួងបន្សាត់បង់ ហើយជាព្រះសង្ឃដល់ហើយនូវកិរិយា សម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។*

(ក្រាបថ្វាយបង្គំម្តង)

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា

(យេ ចាក់ សាំងឃា អាក់តីតា ចាក់ យេ ចាក់ សាំងឃា អាក់ណាគាក់តា)

បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា

(ប៉ាច់ចុបប៉ាន់ណា ចាក់ យេ សាំងឃា អាក់ហាំង

វាន់ទាមិ សាប់ពាក់ទា)

<u>ប្រែថា:</u> *ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសំរេចមគ្គ និង ផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និង ផលកន្លងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និង ផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។*

(ក្រាបថ្វាយបង្គំម្តង)

សុបដិបន្នោ ភគវតោ សាវកសង្ឃោ

(សុប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ សាវ៉ាក់កាក់សាំងឃោ)

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ

(អ៊ុជុប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ សាវ៉ាក់កាក់សាំងឃោ)

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ

(ញាយក្សប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ

សាវ៉ាក់កាក់សាំងឃោ)

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ

(សាម៉ីចិប៉ាក់ដិប៉ាន់ណោ ភាក់គាក់វាក់តោ

សាវ៉ាក់កាក់សាំងឃោ)

យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា

(យក្សទិទាំង ចាត់តារិ ប៉ុរិសាក់យុគានិ

អាត់ថាប៉ុរិសាក់ប៉ុគគាក់លា)

ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ

(អេសាក់ ភាក់គាក់វ៉ាក់តោ សាវ៉ាក់កាក់សាំងឃោ

អាហុណៃយ៉ោ)

បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ

(ប៉ាហុណៃយ៉ោ ទាក់ខិណៃយ៉ោ អាញ់ជាក់លិកាក់រាក់ណីយ៉ោ)

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(អាក់នុតតាក់រ៉ាំង ប៉ុញញាក់ខេតតាំង លោកាស់សាតិ)

<u>**ប្រែថា:**</u> **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌* **ឧជុបដិបន្នោ ភគវ-តោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា* **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង* **សាមីចិបដិបន្នោ ភគវតោ**

សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគលោក ប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីលសមាធិបញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ ជាគូនៃបុរសទាំងឡាយមាន ៤គូរ គឺព្រះសង្ឃ ដែលបានសំរេចនូវ សោតាបត្តិមគ្គ និង សោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និង សកទាគាមិផលជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់ រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃ ដែលបានសំរេចនូវ សោតាបត្តិមគ្គ១ សោតាបត្តិផល១ សកទាគាមិមគ្គ១ សក- ទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរ ទទួលនូវ ចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំ មកអំពីចំងាយ បង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវ អាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និង មិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោន ចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គល ជឿនូវកម្ម និង ផលនៃកម្មហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញ-**

ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ

(ណាត់ថិ មេ សាក់រ៉ាក់ណាំង អាញ់ញ៉ាំង សាំងឃោ

មេ សាក់រ៉ាក់ណាំង វាក់រ៉ាំង)

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

(អេតេនាក់ សាច់ចាក់វាច់ជេនាក់ ហោតុ មេ

ជាក់យក្សម៉ាំងគាក់លាំង)

<u>**ប្រែថា:**</u> **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តី ជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ

(អ៊ុតតាក់ម៉ាំងគេនាក់ វាន់ទេហាំង សាំងឃាញ់ចាក់

ទុវិធោតតាក់ម៉ាំង)

សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

(សាំងឃេ យោ ខាក់លិតោទោសោ សាំងឃោ

ខាក់ម៉ាក់តុ តាំង មាក់មាំង)

__ប្រែថា:__ **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ និង អរិយ សង្ឃ ដោយអវយវៈដ៏ឧត្តម គឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

យោគប្បកោដី

✡✡✡ 📖 ✡✡✡

យោគប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ

(យោកាប់ប៉ាក់កោដីហិប៉ិ អាប់ប៉ាក់ម៉ៃយ៉ាំង កាឡាំង កាក់រ៉ោនតោ)

អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ

(អាក់តិទុកកាក់រ៉ានិ ខេទាំង គាក់តោ លោកាក់ហិតាយក្ស នាថោ)

នមោ មហាការុណិកស្ស តស្ស

(នាក់មោ មាក់ហាការុណិកាស់សាក់ តាស់សាក់)

__ប្រែថា:__ ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្វ ព្រះអង្គកាលប្រាថ្នា

ធ្វើកសាងអស់កាលយូរ រាប់ដោយកោដិកប្បា ច្រើនគណនា ហួសគិតគូរ បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។ ធ្វើកម្មជាកម្រ មនុស្សនិករ ត្រាប់ពុំបានតោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ខ្ញុំសូមឱនសិរសាចិត្ត ប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ

(អាក់សាំពុធាំង ពុទ្ធធាក់និសេវិតាំង យ៉ាំងភាក់វា ភាក់វាំង គាច់ឆាក់តិ)

ជីវលោកោ នមោ អវិជ្ជាទិកិលេសជាលំ

(ជីវាក់លោកោ នាក់មោ អាក់វិចជាទិកិឡេសាក់ ជាលាំង)

វិទ្ធំសិនោ ធម្មវរស្ស តស្ស

(វិទធាំងសិណោ ធ័មមាក់វាក់រាស់សាក់ តាស់សាក់)

<u>**ប្រែថា:**</u> សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល ឲ្យវិលវល់អន្ទោលក្នុងភពតូច និង ភពធំ ហេតុតែមិនដឹងធម៌ជាម្ចាស់ល្អស្អាតសុខុម គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្សការនូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯណាកាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ ។

គុណេហិយោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណប្បវត្តីហិ

(គុណោហិយោ សីឡាក់សាក់ម៉ាធិប៉ាញ៉ញ៉ា

វិមុតតិញ្ញាណាប់ប៉ាក់ភូតីហិ)

យុត្តោ ខេត្តញ្ញូនានំ កុសលត្ថិកានំ

(យុតតោ ខេតតាញ៉ូជាក់នាណាំង កុសាក់ឡាត់ថិកាណាំង)

តមរិយសង្ឃំ សិរសា នមាមិ ។

(តាក់មាក់រិយក្សសាំងឃាំង សិរ៉ាក់សា នាក់មាមិ)

ប្រែថា: ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់គបដោយគុណ សីលត្រង់ និងសមាធិបញ្ញា និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ខ្ញុំសូមឱនសិរសីដល់ព្រះអរិយបុគ្គលជាបុត្រព្រះទសពលជាមង្គលដល់សព្វសត្វ ។

ថ្វាយបង្គំសុំសេចក្ដីសុខ

✡✡✡ 📖 ✡✡✡

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ

(អ៊ិចចេវ៉ាក់ម៉ាច់ចាន់តាក់ នាក់ម៉ាសសាក់ណៃយ៉ាំង)

នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ

(នាក់ម៉ាសសាក់ម៉ាណោ រាត់តាក់ណាត់តាក់យ៉ាំងៗ

ប៉ុញញ៉ាភិសន់ទាំង)

វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ ។

(វិប៉ុឡាំង អាក់ឡាត់ថាំង តាស់សានុភាវេនាក់ ហាក់តន់តាក់រ៉ាយ៉ោ)

ប្រែថា: ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសារធំទូលាយ សូមឲ្យកំចាត់បង់ អពមង្គលទាំងឡាយ ឲ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់សល់ឋាននិព្វានហោង ។

(ចប់ធម៌យោកប្បកោដិ)

ធម្មោ ហវេ រក្ខតិ ធម្មចារឹ

ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តិធម៌

នមស្ការបូជនីយវត្ថុជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ

(វ៉ាន់ទាមិ ចេតិយ៉ាំង សាប់ពាំង សាប់ពាក់ថានេសុ

ប៉ាក់តិដថិតាំង)

សារីរិកធាតុ មហាពោធិំ ពុទ្ធរូបំ សកលំ សទា ។

(សារីរិកាក់ធាតុ មាក់ហាពោធឹង ពុទ្ធាក់រូប៉ាំង

សាក់កាក់ឡាំង សាក់ទា)

ប្រែថា: *ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ*

ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។

និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត

លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។

និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី

ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។

ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់

ដែលតែងតែរំលស់ រដោះទុក្ខភ័យអន្តរាយ ។

សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ

សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត ។

សូមទាន់ព្រះអរិ- យមេត្រៃយ្យថ្លៃវិសិដ្ឋ

សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

ពុទ្ធបាទនមស្សការគាថា

✡✡✡ 📖 ✡✡✡

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ

(វ៉ាន់ទាមិ ពុទ្ធផាំង ភាក់វ៉ាក់ប៉ាវាក់តិនណាំង តិលោកាក់កេតតុំ)

តិភវេកនាថំ យោលោកសេដ្ឋោ សកលំ

(តិភាក់វេកាក់នាថាំង យោលោកាក់សេដថោ សាក់កាក់ឡាំង)

កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

(កិឡេសាំង ឆេតត្វានាក់ ពោធេសិ ជាក់ណាំង អាក់នន់តាំង)

<u>ប្រែថា:</u> *ជាពាក្យកាព្យ*

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មមារណាប្រៀបដូចបាន ។
កម្ចាត់នូវកិលេស គ្មានឲ្យសេសនៅសល់ខាន
ញុំាងជនទាំងប៉ុន្មាន ជាអនន្តឲ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេព្តា និងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ

(យ៉ាំង ណាំមាក់ទាយក្ស នាក់ទិយា ប៉ុលិនេ ចាក់ តីរ៉េ យ៉ាំង)

សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ

(សាច់ចាក់ពាន់ធាក់គិរិកេ សុមាក់នាចាក់លាគគេ

យ៉ាំង តាត់ថាក់)

យោនកបុរេ មុនិនោ ច បាទំ តំ

(យោនាក់កាក់ប៉ុរ៉េ មុនិនោ ចាក់ ប៉ាទាំង តាំង)

បាទលញ្ឆនមហំ សិរសា នមាមិ

(ប៉ាទាក់ឡាញ់ជាក់នាក់មាក់ហាំង សិរ៉ាក់សា នាក់មាមិ)

សូមថ្វាយបង្គំ ទសករប្រណម្យ ឆ្ពោះត្រង់ស្នាមព្រះបាទា

ដែលព្រះមានជោគ ទ្រង់ព្រះមេត្តា ជាន់ទុកឲ្យជាស្ពានថ្លៃ ។

ព្រះបាទមួយនៅនា ស្ទឹងនម្មទា ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ

ព្រះបាទមួយទ្រង់ជាន់ ទុក្ខនៅព្ធ- ដ៏ភ្នំគិរីសច្ចព័ន្ធ ។

ព្រះបាទមួយនៅភ្នំ សុមនកូដ រហូតកំពូលដ៏សោភ័ណ

ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ ទុកនៅនាយោនកបុរី ។

ខ្ញុំសូមបន្ទន់ កាយវាចា និងចិត្តជ្រះថ្លាឱនសិរសី

បង្គំព្រះបាទ ព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ

(*សុវ៉ាន់ណាក់មាលិកេ សុវ៉ាន់ណាក់ប៉ាប់ពាក់តេ សុមាក់នាក់កូដេ*)

យោនកបុរេ នម្មទាយ នទិយា

(*យោនាក់កាក់ប៉ុរ៉េ ណាំមាក់ទាយក្យ នាក់ទិយា*)

បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

(*ប៉ាញ់ចាក់ប៉ាទាក់វ៉ាក់រ៉ាំង ឋាណាំង អាក់ហាំង វ៉ាន់ទាមិ ទូរ៉ាក់តោ*)

ខ្ញុំសូមនមស្សការ អំពីចម្ងាយ នូវឋានទាំងឡាយ
ដែលមានព្រះបាទ ទាំងប្រាំកន្លែង ដែលព្រះមុនីនាថ
ទ្រង់យាងព្រះបាទ លើកំពូលភ្នំ ។
សុវណ្ណមាលិក មួយនោះជាធំ មួយនៅលើភ្នំ សុវណ្ណ
បពិត មួយនៅលើភ្នំ សុមនកូដប្រាកដ
មួយនៅរាជរដ្ឋ យោនកមបុរី ។
មួយនៅក្បែរស្ទឹង នម្មទាជលធី ទាំងប្រាំនាទី
ដែលទ្រង់ប្រទាន ទុកឲ្យសព្វសត្វ ប្រតិបត្តិជាស្ពាន
ដែលព្រះទ្រង់ញាណ ប្រទានទុកឲ្យ ។

ច្បាលីយកវត្តព្រះ

✡✡✡ 📖 ✡✡✡

ឱកាស វន្ទាមិ ភន្តេ (ភគវា) សព្វំ អបរាធំ ខមថ

(អ៊ុកាសាក់ វ៉ាន់ទាមិ ភាន់តេ "ភាក់គាក់វ៉ា" សាប់ពាំង

អាក់ប៉ាក់រ៉ាធាំង ខាក់មាក់ថាក់)

មេ ភន្តេ មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ

(មេ ភាន់តេ មាក់យ៉ា កាក់តាំង ប៉ុញញ៉ាំង សាមិណា

អាក់នុមោទិតាប់ពាំង)

សាមិនា កតំ បុញ្ញំ មយ្ហំ ទាតព្វំ សាធុ សាធុ អនុមោទាមិ ។

(សាមិណា កាក់តាំង ប៉ុញញ៉ាំង មៃហាំង ទាតាប់ពាំង

សាធុៗ អាក់នុមោទាមិ)

រួចហើយអង្គុយច្រហោងប្រណម្យអញ្ជលី សូត្រថា៖

សព្វំ អបរាធំ ខមថ មេ ភន្តេ ។

(សាប់ពាំង អាក់ប៉ាក់រ៉ាធាំង ខាក់មាក់ថាក់ មេ ភាន់តេ)

ក្រាបចុះ សូត្រថា៖

ឱកាស ទ្វារត្តយេន កតំ សព្វំ អបរាធំ

(អ៊ុកាសាក់ ទ្វារាត់តាក់យេនាក់ កាក់តាំង សាប់ពាំង

អាក់ប៉ាក់រ៉ាធាំង)

ខមថ មេ ភន្តេ ។ *(ខាក់មាក់ថាក់ មេ ភាន់តេ)*

សុំខមាទោស

ឱកាស ខមាមិ ភន្តេ[១] **។** *(អ៊ុកាសាក់ ខាក់ម៉ាមិ ភាន់តេ)*

ទើបសូត្រម្ដងទៀតថា:

វន្ទាមិ ភន្តេ ។ល។ សាធុ សាធុ អនុមោទាមិ ។

(វ៉ាន់ទាមិ ភាន់តេ ។ល។ សាធុ សាធុ អាក់នុមោទាមិ)

(ចប់វិធីយកវត្តព្រះតៃប៉ុណ្ណេះ)

ចិត្តំ ទន្តំ សុខាវហំ

ចិត្តដែលគេទូន្មានបានល្អហើយ នាំសេចក្ដីសុខមកឲ្យ

សុខោ បញ្ញាបដិលាភោ

ការបាននូវបញ្ញា នាំមកនូវសេចក្ដីសុខ

វិធីសមាទានសីល៥ (និច្ចសីល)

✡✡✡ 🕮 ✡✡✡

ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

(អ៊ុកាសាក់ មាក់យ៉ាំង ភាន់តេ វិស៊ុំងៗ រាក់ខាក់ណាត់ថាយក្យ)

តិសរណេន សហ បញ្ចសីលានិ យាចាម ។

(តិសាក់រាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីឡានិ យាចាមាក់)

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

(ទុតិយ៉ាំងប៉ិ មាក់យ៉ាំង ភាន់តេ វិស៊ុំងៗ រាក់ខាក់ណាត់ថាយក្យ)

តិសរណេន សហ បញ្ចសីលានិ យាចាម ។

(តិសាក់រាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីឡានិ យាចាមាក់)

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

(តាក់តិយ៉ាំងប៉ិ មាក់យ៉ាំង ភាន់តេ វិស៊ុំងៗ រាក់ខាក់ណាត់ថាយក្យ)

តិសរណេន សហ បញ្ចសីលានិ យាចាម ។

(តិសាក់រាក់ណេនាក់ សាក់ហាក់ ប៉ាញ់ចាក់សីឡានិ យាចាមាក់)

អនុគ្គហំ កត្វា សីលំ ទេថ [**មេ** (មេ) / **នោ** (នោ)] **ភន្តេ ។**
(អាក់នុគគាក់ហាំង កាត់ត្វា សីឡាំង ទេថាក់ [មេ / នោ] *ភាន់តេ*

(ទើបព្រះសង្ឃសូត្រថា)

នមោ តស្ស ភគវតោ អរហតោ *(នាក់មោ តាស់សាក់ ភាក់គាក់វាក់តោ អាក់រ៉ាក់ហាក់តោ)*
សម្មាសម្ពុទ្ធស្ស ។ *(សាំម៉ាសាំពុទ្ធធាស់សាក់)*
(សូត្របីដង)

ពុទ្ធំ សរណំ គច្ឆាមិ *(ពុទ្ធធាំង សាក់រ៉ាក់ណាំង គាច់ឆាមិ)*
ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក
ធម្មំ សរណំ គច្ឆាមិ *(ធ័មមាំង សាក់រ៉ាក់ណាំង គាច់ឆាមិ)*
ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក
សង្ឃំ សរណំ គច្ឆាមិ *(សាំងឃាំង សាក់រ៉ាក់ណាំង គាច់ឆាមិ)*
ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក
ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ *(ទុតិយាំបុិ...)*
ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭកជាគម្រប់ពីរដងផង
ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ *(ទុតិយាំបុិ...)*

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭកជាគម្រប់ពីរដង ផង

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ (*ទុតិយុាំប៉ិ...*)

ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭកជាគំរប់ពីរដងផង

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ (*តាក់តិយុាំប៉ិ...*)

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរឭកជាគម្រប់បីដងផង

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ (*តាក់តិយុាំប៉ិ...*)

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭកជាគម្រប់បីដងផង

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ (*តាក់តិយុាំប៉ិ...*)

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭកជាគម្រប់បី ដងផង ។

(ចប់ព្រះត្រៃសរណគមន៍)

- *ព្រះសង្ឃសូត្រថា:* **តិសរណគមនំ បរិបុណ្ណំ**

(តិសាក់រ៉ាក់ណាក់គាក់ហាក់ណាំង ប៉ាក់រិប៊ុនណាំង)

ប្រែថា: *ការកាន់យកសរណគមន៍ ៣ ពេញបរិបូណ៌ ។*

ឧបាសក-សិកាថា: **អាម ភន្តេ** (**ប្រែថា**) *ករុណាជាម្ចាស់ ។*

១. បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ

(ប៉ាណាតិប៉ាតា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២. អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ

(អាក់ទិននាទានា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចារ ។

៣. កាមេសុមិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ

(កាម៉េសុមិចឆាចារ៉ា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៤.មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ

(មុសាវាទា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ

សមាទិយាមិ

(សុរ៉ាមេរាក់យក្សម៉ាច់ជាប់ប៉ាក់ម៉ាទាត់ឋាណា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

ប្រែថា: *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។*

ព្រះសង្ឃសូត្ររំលឹកថា

ឥមានិ បញ្ចសិក្ខាបទានិ សាធុកំ កត្វា

(អ៊ិម៉ានិ ប៉ាញ់ចាក់សិកខាប៉ាក់ទានិ សាធុកាំង កាត់ត្វា)

អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។

(អាប់ប៉ាក់ម៉ាទេនាក់ និចចាក់កាឡាំង សាំម៉ារ៉ាក់ខិតាប់ពាំង)

ប្រែថា: *អ្នក (អ្នកទាំងឡាយ) គប្បីធ្វើនូវសិក្ខាបទទាំងឡាយទាំង ៥ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទគឺថាកុំបីធ្វេសប្រហែសឡើយ។*

ឧបាសក-សិកា: **អាម ភន្តេ** *(ករុណាលោកម្ចាស់)* ។

អានិសង្សសីល

✡✡✡ 🕮 ✡✡✡

សីលេន សគតឹ យន្តិ សីលេន ភោគសម្បទា

(សីឡេនាក់ សុគាក់តឹង យ័ន្តតិ សីឡេនាក់ ភោគាក់សាំប៉ាក់ទា)

សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

(សីឡេនាក់ និពពុតឹង យ័ន្តតិ តាស់ស្មា សីឡាំង វិសោធាក់យេ)

__**ប្រែថា:**__ សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគ: ក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះបុគ្គលជាសប្បុរស គប្បីជម្រះនូវសីលរបស់ខ្លួនអោយបរិសុទ្ធកុំ ឲ្យ សៅហ្មង ។

__ឧបាសក-សិកា:__ **សាធុ សាធុៗ** ប្រពៃ ប្រពៃៗ ។

(ចប់វិធីសមាទានសីល ៥ តែប៉ុណ្ណោះ)

សទ្ធា ពន្ធតិ បាថេយ្យំ

សទ្ធាវេចខ្ចប់នូវស្បៀង (គឺកុសល)

វិធីសមាទានសីល ៨ ឧបោសថ

✡✡✡ 🕮 ✡✡✡

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

(អ៊ុកាសាក់ មាក់យ៉ាំង ភាន់តេ វិស៊ុងៗ រាក់ខាក់ណាត់យក្ស)

តិសរណេន សហ អដ្ឋង្គសមន្នាគតំ

(តិសាក់រ៉ាក់ណេនាក់ សាក់ហាក់

អាត់ថាំងគាក់សាក់ម៉ន់ណាគាក់តាំង)

ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ

(អ៊ុប៉ោសាក់ថាំង យាចាមាក់ អាក់នុគគាក់ហាំង

កាត់ត្វា សីឡាំង)

ទេថ នោ ភន្តេ ។ (*ទេថាក់ នោ ភាន់តេ*)

ទុតិយម្បិ (*ទុតិយ៉ាំប៉ិ*)	**មយំ ភន្តេ វិសុំ......។**
តតិយម្បិ (*តាក់តិយ៉ាំប៉ិ*)	

☆ *<u>ចំណាំថា:</u> បន្ទាប់អំពីព្រះសង្ឃឲ្យត្រៃសរណគមន៍រួច ទើបទទួលថា:*

១. បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ

(ប៉ាណាតិបាតា វេរ៉ាក់មាក់នីសិកខាប៉ាក់ទាំង សាក់មាទិយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសំលាប់សត្វ ។

២. អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ

(អាក់ទិននាទានា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចារ ។

៣. អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ

(អាក់ប្រាំមាក់ចាក់រិយា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយានូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤. មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ

(មុសាវាទា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ

(*សុរ៉ាមេរាក់យក្សម៉ាច់ផាប់ប៉ាក់ម៉ាទាត់ឋាណា*
វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

ប្រែថា: *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។*

៦. វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ

(*វិកាឡាក់ភោជាក់នា វេរាក់មាក់នីសិកខាប៉ាក់ទាំង*
សាក់ម៉ាទីយាមិ)

ប្រែថា: *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។*

៧. នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានាវេរមណីសិក្ខាបទំសមាទិយាមិ

(*នាច់ចាក់គីតាក់វាទិតាក់វិសូកាក់ទាស់សាក់ណាក់មាលាគន់ធាក់វិលេប៉ាក់នាក់ធារាក់ណាក់ម៉ន់ឌាក់នាក់វិភូសាក់ណា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ*)

ប្រែថា: *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំនិងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និង កិរិយាទ្រទ្រង់ និង ប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និង គ្រឿងក្រអូប*

និង គ្រឿងលាបផ្សេងៗ ។

៨. ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ

(អ៊ុចចាសាក់យក្សនាក់មាក់ហាសាក់យក្សណា វេរាក់មាក់នីសិក ខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

<u>**ប្រែថា:**</u> *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈក៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។*

ឧបាសក-ឧបាសិកាសូត្របន្តទៀតថា:

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ

(អ៊ិមាំង អាត់ឋាំងគាក់សាក់ម៉ន់ណាគាក់តាំង ពុទ្ធចាប់ប៉ាញ់ញាត់តាំង)

ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ

(អ៊ុប៉ោសាក់ថាំង អ៊ិម៉ាញ់ចាក់រាត់តឹង អ៊ិម៉ាញ់ចាក់ទិវាក់សាំង)

សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។

(សាំមាក់ទេវាក់អាក់ភិរាក់ខិតុង សាក់ម៉ាទិយាមិ)

<u>**ប្រែថា:**</u> *ខ្ញុំព្រះករុណា សូមសមាទាន នូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្ត*

ទុកហើយនេះ ដើម្បីរក្សាឲ្យបរិបូណ៌ប្រពៃអស់កាលកំណត់ថ្ងៃនេះ និង យប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឲ្យច្បាស់នូវព្រះនិព្វាន ដ៏អនាគតទៅឯមុខនោះហោង ។

<u>*ព្រះសង្ឃសូត្ររំលឹកថា:*</u>

ឥមានិ អដ្ឋសិក្ខាបទានិ ឧបោសថសីលវសេន

(អ៊ិម៉ានិ អាត់ឋាក់សិកខាប៉ាក់ទានិ អ៊ុប៉ោសាក់ថាក់

សីលាក់វ៉ាក់សេនាក់)

ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា

(អ៊ិម៉ាញ់ចាក់រាត់តឹង អ៊ិម៉ាញ់ចាក់ទិវ៉ាក់សាំង

សាធុកាំង កាត់ត្វា)

អប្បមាទេន សម្មា រក្ខិតព្វំ ។

(អាប់ប៉ាក់ម៉ាទេនាក់ សាំម៉ារាក់ខិតាប់ពាំង)

<u>**ប្រែថា:**</u> *អ្នក (អ្នកទាំងឡាយ) គប្បីធ្វើនូវសិក្ខាបទទាំង៨នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយអំណាចឧបោសថសីលអស់កាលកំណត់ត្រឹម ១ថ្ងៃ ១យប់ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។*

ឧបាសក-សិកាទទួលថា: **អាម ភន្តេ** *ករុណាលោកម្ចាស់។*

អានិសង្សសីល

✡✡✡ 📖 ✡✡✡

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា

(សីលេនាក់ សុគាក់តឹង យ័ន្តតិ សីលេនាក់ ភោគាក់សាំប៉ាក់ទា)

សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

(សីលេនាក់ និពពុតឹង យ័ន្តតិ តាស់ស្មា សីឡាំង វិសោធាក់យេ)

__ប្រែថា:__ *សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះបុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឲ្យបរិសុទ្ធកុំឲ្យសៅហ្មង ។*

__ឧបាសក-សិកា:__ **សាធុ សាធុៗ** *(ប្រ៊ពៃ ប្រ៊ពៃៗ) ។*

(ចប់វិធីសមាទានសីល ៨ តែប៉ុណ្ណោះ)

ធនតោ បុញ្ញំ បវឌ្ឍតិ

បុណ្យរមែងចំរើនដល់អ្នកអោយទាន

សមាទានសីល ១០

✡✡✡ 📖 ✡✡✡

អ្នកសមាទានសីល ១០ មុននឹងសុំសីល ត្រូវនមស្សការរំលឹកគុណព្រះរតនត្រ័យសិនហើយសូត្រសូមជាភាសាបាលីថា:

ឧកាស អហំ ភន្តេ តិសរណេន សហ ទស

(អ៊ុកាសាក់ អាក់ហាំង ភាន់តេ តិសាក់រ៉ាក់ណេនាក់ សាក់ហាក់ ទាក់សាក់)

សីលានិ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ

(សីឡានិ យាចាមិ អាក់នុគាក់ហាំង កាត់ត្វា សីឡាំង ទេថាក់ មេ ភាន់តេ)

ប្រែថា: *សូមគោរព ទានប្រោស ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង ទានប្រោសសូមព្រះករុណា ធ្វើនូវសេចក្តីអនុគ្រោះឲ្យនូវសីលដល់ខ្ញុំព្រះករុណា ។*

ទុតិយម្បិ អហំ ភន្តេ ។ល។ សីលំ ទេថ មេ ភន្តេ

(ទុតិយ៉ាំងប៉ិ អាក់ហាំង ភាន់តេ ។ល។ សីឡាំង ទេថាក់ មេ ភាន់តេ)

ប្រែថា: *សូមគោរព ទានប្រោស ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង ទានប្រោស សូម*

ព្រះករុណា ធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុ-ណា ។ អស់វារៈជាគំរប់ពីរដងផង ។

តតិយម្បិ អហំ ភន្តេ ។ល។ សីលំ ទេថ មេ ភន្តេ

(តាក់តិយាំងបិ អាក់ហាំង ភាន់តេ ។ល។ សីឡាំង ទេថាក់ មេ ភាន់តេ)

ប្រែថា: សូមគោរព ទានប្រោស ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង ទានប្រោសសូមព្រះករុណា ធ្វើនូវសេចក្តីអនុគ្រោះអោយនូវសីលដល់ខ្ញុំព្រះករុ-ណា ។ អស់វារៈជាគំរប់បីដងផង ។

បើគ្នាច្រើនថា មយំ ភន្តេ ថា យាចាម (**មយំ** ប្រែថា " **យើងខ្ញុំទាំងឡាយ** ")។ ត្រង់ **មេ ភន្តេ** ត្រូវថា **នោ ភន្តេ** (**នោ** ប្រែថា " ដល់យើងខ្ញុំព្រះករុណាទាំងឡាយ ") ។

កាលបើ ឧបាសក ឧបាសិកា សូមសីលព្រមទាំងត្រៃសរណគមន៍រួចហើយ លោកអ្នកឲ្យសីលគួរពោលពាក្យថា:

យមហំ វទាមិ តំ វទេហិ (យក្សមាក់ហាំង វាក់ទាមិ តាំង វាក់ទេហិ) "អាត្មាពោលនូវពាក្យណា ចូរអ្នកពោលនូវពាក្យនោះ " ។ បើឧបាសកឧបាសិកាច្រើន តាំងពីពីរនាក់ឡើងទៅលោកឲ្យសីលត្រូវពោលថា: **យមហំ វទាមិ តំ វទេថ** (យក្សមាក់ហាំង វាក់ទាមិ តាំងវាក់ទេថាក់) " អាត្មាពោលនូវ ពាក្យ

ណា អ្នកទាំងឡាយចូរពោលនូវពាក្យនោះ ” ។ **អ្នកទទួលសីល ត្រូវតបថា: អាម ភន្តេ** *“ ព្រះករុណាទានប្រោស ” ។ រួចលោកអ្នកឲ្យសីលសូត្រថា:*

នមោ តស្ស ។ល។ សម្មាសម្ពុទ្ធស្ស (*សូត្របីដង*) ។

រួចលោកឲ្យនូវត្រៃសរណគមន៍ និងសិក្ខាបទតទៅទៀត:

ពុទ្ធំ សរណំ គច្ឆាមិ ។ ធម្មំ សរណំ គច្ឆាមិ ។ សង្ឃំ សរណំ គច្ឆាមិ ។ល។ តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ។

១. បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ

(ប៉ាណាតិបាតា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់មាទិយាមិ)

<u>**ប្រែថា:**</u> *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។*

២. អទិន្នាទានា វេរមណីសិក្ខាបទំ សមាទីយាមិ

(អាក់ទិននាទានា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទិយាមិ)

<u>**ប្រែថា:**</u> *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចារ ។*

៣. អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទីយាមិ

(អាក់ប្រាំមាក់ចាក់រិយា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ា ទិយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយានូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤. មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ

(មុសាវ៉ាទា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ

(សុរ៉ាមេរាក់យក្សម៉ាច់ជាប់ប៉ាក់ម៉ាទាត់ឋាណា
វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុ ជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរា និង មេរ័យ ។

៦. វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ

(វិកាលាក់ភោជាក់នា វេរាក់មាក់នីសិកខាប៉ាក់ទាំង
សាក់ម៉ាទីយាមិ)

<u>ប្រែថា:</u> ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជា

ហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

៧. នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ សមាទិយាមិ

(នាច់ចាក់គីតាក់វាទិតាក់វិសូកាក់ទាក់សាក់នា វេរាក់មាក់នី សិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

__ប្រែថា:__ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំនិងច្រៀង និង ប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។

៨. មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

(មាលាគាន់ធាក់វិលេប៉ាក់នាក់ធារាក់ណាក់ម៉ាន់ឌាក់នាក់វិភូសាក់ណាត់ថាណា វេរាក់មាក់នីសិកខាប៉ាក់ទាំង...)

__ប្រែថា:__ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់នូវប្រដាប់ តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកំរងនិង គ្រឿងក្រអូបនិង គ្រឿងលាបផ្សេងៗ ។

៩. ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ

(អ៊ុចចាសាក់យក្សនាក់មាក់ហាសាក់យក្សណា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

ប្រែថា: ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈក៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

១០. ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ

(ជាតាក់រូប៉ាក់រាក់ជាក់តាប់ប៉ាក់ដិគគាក់ហាក់ណា វេរាក់មាក់នីសិកខាប៉ាក់ទាំង សាក់ម៉ាទីយាមិ)

ប្រែថា: ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាស និង ប្រាក់ដោយខ្លួនឯង ឬ ប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាស និង ប្រាក់នោះ ។

លុះអ្នកទទួលសីល ១០ ចប់ហើយ លោកអ្នកឲ្យសីលគួរប្រាប់បញ្ជាក់ថា:

ឥមានិ ទស សិក្ខាបទានិ អប្បមាទេន សម្មារក្ខិតព្វំ

(អ៊ិម៉ានិទាក់សាក់ សិកខាប៉ាក់ទានិ អាប់ប៉ាក់ម៉ាទេនាក់សាំម៉ារាក់ខិតាប់ពាំង)

" អ្នកត្រូវរក្សាដោយប្រពៃនូវសិក្ខាបទទាំងឡាយ ១០ នេះ កុំបីធ្វេសប្រហែសឡើយ "

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** " ព្រះករុណា ទាន

ប្រោស” ។ លំដាប់មកទៀត លោកអ្នកឲ្យសីលសំដែងអានិសង្ស សីលដោយសង្ខេប ឬ ដោយពិស្តារឲ្យអ្នកសមាទានស្តាប់តាមកាល ដ៏គួរ តាមតែសំដែងអានិសង្សសីលត្រង់ណា ក៏បានតាមសមត្ថភាព របស់លោកអ្នកឲ្យសីល ។

អានិសង្សសីល

✡✡✡ 📖 ✡✡✡

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា

(សីលេនាក់ សុគាក់តឹង យ័ន្តតិ សីលេនាក់ ភោគាក់សាំប៉ាក់ទា)

សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

(សិលេនាក់ និពពុតឹង យ័ន្តតិ តាស់ស្មា សីឡាំង វិសោធាក់យេ)

__ប្រែថា:__ សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះបុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឲ្យបរិសុទ្ធកុំឲ្យសៅហ្មង ។

អ្នកទទួលសីលថា : **សាធុ សាធុៗ** (ប្រពៃ ប្រពៃៗ) ។

បែបអ្នករក្សាសីល ១០

✡✡✡ 📖 ✡✡✡

ឧបាសកឧបាសិកាអ្នករក្សាសីល ១០ ត្រូវកោរសក់ បើមានពុកមាត់ពុកចង្កា ក៏ត្រូវកោរផងដែរ ត្រូវកាត់ក្រចកដៃជើងឲ្យស្មើនឹងសាច់ ត្រូវស្លៀកពាក់ស ឬ ពានាសំពត់សផងក៏បាន តាមគួរដល់ការលៃលកឲ្យសមរម្យតាមសភាពបុរស និង ស្ត្រី ។ សីលកើតមានឡើងដោយសារវិរតិចេតនា ពុំមែនដោយសារកោរសក់ស្លៀកពាក់សទេ ក៏ពិតមែនហើយ ប៉ុន្តែការកោរសក់ស្លៀកពាក់សនេះ ជាបវរណីមួយសម្រាប់គ្រហស្ថ អ្នកកាន់សីល ១០ ក្នុងព្រះពុទ្ធសាសនា ជាគ្រឿងសំគាល់ឲ្យឃើញប្លែកពីគ្រហស្ថទាំងពួង ទាំងជាភស្តុតាងដល់ផ្លូវចិត្តរបស់គ្រហស្ថអ្នកកាន់សីល ១០ នោះផងទៀត ប៉ុន្តែកុំយល់ថាដូចគ្នានឹងអ្នកដែលស្លៀកពាក់សតាមធម្មតា ឬ អ្នកដែលកោរសក់ កោរពុកមាត់ ពុកចង្ការតាមធម្មតា ឥតបានសមាទាន កាន់សីលសោះនោះឡើយ ។ អ្នកកាន់សីល និង អ្នកមិនកាន់សីលមានសភាពផ្សេងផ្ទុយគ្នាដោយផ្លូវចិត្តដោយចរិយា និង គុណសម្បត្តិ សូម្បីអ្នកមានសីលផងគ្នា ក៏គង់ផ្សេងទីទៃពីគ្នា ដោយថ្នាក់សីលធម៌ដែរ គឺភិក្ខុ មានសីលខ្ពស់ជាងសាមណេរ សាមណេរមានសីល

ខ្ពស់ជាងគ្រហស្ថអ្នកកាន់សីល១០ គ្រហស្ថអ្នកសីល១០ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល៨ អ្នកកាន់សីល៨ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៥ ។

អ្នកកាន់សីលទាំងនេះ សុទ្ធតែគួរគោរពគ្នា តាមលំដាប់ថ្នាក់សីល ទាំងតាមលំដាប់ថ្នាក់អាយុវស្សាចាស់ ក្មេង ហើយនឹងគុណសម្បត្តិផងទៀត ទើបសមគួរតាមលំអានគន្លងគារវធម៌ក្នុងព្រះពុទ្ធសាសនា និង បោរាណកធម៌ ក្នុងកាលព្រេងនាយ សូម្បីសត្វតិរច្ឆានធំតូចដូចយ៉ាងសត្វ ទទា ស្វា ដំរី ដែលចេះគោរពគ្នាតាមលំដាប់ថ្នាក់ អាយុចាស់ ក្មេង ក៏អាចបានសុគតិភពជាទិដ្ឋានុគតិ ឲ្យមនុស្សយកតម្រាប់បានដែរ ។

បណ្ឌិតោ សីលសម្បន្នោ ជលំ អគ្គីវ ភាសតិ

បណ្ឌិតបរិបូណ៌ដោយសីល រមែងរុងរឿងដូចភ្លើងភ្លឺ

អង្គនៃនិច្ចសីល

✡✡✡ 🕮 ✡✡✡

ទី ១ បាណាតិបាត មានអង្គ ៥

១. **បាណោ** (ប៉ាណោ) សត្វមានជីវិត

២. **បាណសញ្ញិតា** (ប៉ាណាក់សាញ់ញិតា) សេចក្តីដឹងថាសត្វមានជីវិត

៣. **វធកចិត្តំ** (វាក់ធាក់កាក់ចិតតាំង) គិតនឹងសម្លាប់

៤. **ឧបក្កមោ** (អ៊ុប៉ាក់កាក់ម៉ោ) ព្យាយាមនឹងសម្លាប់

៥. **តេន មរណំ** (តេនាក់មាក់រាក់ណាំង) សត្វស្លាប់ដោយការព្យាយាមនោះ ។

ទី ២ អទិន្នាទាន មានអង្គ ៥

១. **បរបរិគ្គហិតំ** (ប៉ាក់រាក់ប៉ាក់រិគគាក់ហិតាំង) ទ្រព្យដែលម្ចាស់ របស់គេហួងហែងរក្សា

២. **បរបរិគ្គហិតសញ្ញិតា** (ប៉ាក់រាក់ប៉ាក់រិគគាក់ហិតាក់សាញ់ញិតា) សេចក្តីដឹងថាទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា

៣. **ថេយ្យចិត្តំ** (ថៃយក្យចិតតាំង) គិតនឹងលួច

៤. **ឧបក្កមោ** (អ៊ុប៉ាក់កាក់ម៉ោ) ព្យាយាមនឹងលួច

៥. ថេនហរណំ (តេនាក់ហាក់រាក់ណាំង) លួចបានមកដោយព្យាយាមនោះ ។

ទី ៣ កាមេសុមិច្ឆាចារ មានអង្គ ៤

១. អគមនីយដ្ឋានំ (អាក់គាក់មាក់ណីយ៉ាតថាណាំង) ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា។
២. តស្មឹសេវនចិត្តំ (តាស់ស្មឹងសេវាក់នាក់ចិតតាំង) គិតនឹងសេពនូវមេថុនធម្ម នឹងស្ត្រីនោះ
៣. ឧបក្កមោ (អ៊ុប៉ាក់កាក់ម៉ោ) ព្យាយាមនឹងសេពនូវមេថុនធម្ម
៤. មគ្គេនមគ្គបដិបាទនំ (មាគ់គេនាក់មាគ់គាក់ប៉ាក់ដិប៉ាទាក់ណាំង) ញ៉ាំងមគ្គ និង មគ្គឲ្យដល់គ្នា ។

ទី ៤ មុសាវាទ មានអង្គ ៤

១. អតថំវត្ថុ (អាក់តាក់ថាំងវ៉ាតថុ) វត្ថុមិនពិត
២. វិសំវាទនចិត្តំ (វិសាំងវាទាក់នាក់ចិតតាំង) គិតនឹងពោលឲ្យខុស
៣. តជ្ជោវាយាមោ (តាច់ជោវាយោមោ) ព្យាយាមនឹងពោលឲ្យ ខុស

៤.បរស្សេតទត្តចិដានំ (*ប៉ាក់រ៉ាស់សាក់តាក់ទាត់តាក់វិជានាក់ណាំង) ញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្ដីនោះ ។*

<u>ទី ៥ សុរាមេរយ មានអង្គ ៤</u>

១. មជ្ជនីយវត្ថុ (*ម៉ាច់ជាក់ណីយក្សវ៉ាត់ថុ) វត្ថុជាទីតាំងនៃសេចក្ដីស្រវឹង គឺសុរា និង មេរ័យ ។*

២. បាតុកម្យតាចិត្តំ (*ប៉ាតុកាំយក្សតាចិត្តតាំង) គិតបំរុងនឹងផឹក*

៣. តជ្ជោ វាយាមោ (*តាច់ជោ វាយោមោ) ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។*

៤. តស្ស បានំ (*តាស់សាក់ប៉ាណាំង) បានផឹកនូវទឹកស្រវឹងនោះ អោយកន្លងបំពង់កចូលទៅ ។*

កាលបើឧបាសក ឧបាសិកា ប្រព្រឹត្តឲ្យកន្លងនូវសិក្ខាបទណាៗ លុះត្រាតែព្រមដោយអង្គក្នុងសិក្ខាបទនោះៗ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះៗទេ។ គ្រាន់តែសីលនោះ ពព្រុះពពាល ដូចគេប្រាយលាច ។

ភាពស្អាតរបស់សីលមាន ៣យ៉ាងគឺ:

១. កាយសោចយ្យ (*កាយក្សសោចីយក្ស) ភាពស្អាតកាយ*

២. វចីសោចយ្យ (*វ៉ាក់ចីសោចីយក្ស*) *ភាពស្អាតវាចា*

៣. មនោសោចយ្យ (*មាក់នាក់សោចីយក្ស*) *ភាពស្អាតចិត្ត ។*

សីលមានធម៌ ២យ៉ាងជាបទដ្ឋាន *(ហេតុជិត)*

១. ហិរិ *សេចក្តីខ្មាស់បាប*

២. ឱត្តប្ប *សេចក្តីតក់ស្លុត នឹងអំពើបាន ឬក្រែងខ្លាចបាប*

តាមសេចក្តីពិតថាកាលដែល ហិរិ និង ឱត្តប្ប មានសីលរមែងកើតឡើងផង ស្ថិតនៅផង តែបើ ហិរិ និង ឱត្តប្ប មិនមានទេនោះ សីលក៏មិនកើតឡើងមិនស្ថិតនៅ ។

អានិសង្សរបស់សីល

✡✡✡ 📖 ✡✡✡

សីលរបស់បុគ្គល ដែលបានសមាទានហើយ ដុះខាត់ឲ្យស្អាតផូរផង់បរិសុទ្ធ នឹងមានអានិសង្សច្រើនក្នុងគម្ពីរ វិសុទ្ធិមគ្គមានសេចក្តីថា កាលបើសីលបរិសុទ្ធហើយ ជាបច្ច័យឲ្យកើត អវិប្បដិសារៈ សេចក្តីមិនក្តៅក្រហាយស្តាយក្រោយ ។

កាលបើអវិប្បដិសារៈកើតឡើងហើយ ជាបច្ច័យឲ្យកើតបាមោជ្ជៈគឺ សេចក្តីរីករាយទន់ កាលបើបាមោជ្ជៈកើតឡើងហើយ ជាបច្ច័យឲ្យកើត បីតិ សេចក្តីឆ្អែតចិត្ត កាលបើបាបីតិ

កើតឡើងហើយ ជាបច្ច័យឲ្យកើត បស្សទ្ធិ សេចក្តីស្ងប់កាយចិត្ត កាលបើបស្សទ្ធិ កើតឡើងហើយ ជាបច្ច័យឲ្យកើតសុខសេចក្តីស្រួលកាយ ចិត្ត កាលបើ សុខកើតឡើងហើយ ជាបច្ច័យឲ្យកើត សមាធិ ការតម្កល់ចិត្តឲ្យនឹង កាលបើសមាធិកើតឡើងហើយ ជាបច្ច័យឲ្យកើត យថាភូតញ្ញាណទស្សនប្រាជ្ញា ដែលដឹងច្បាស់ឃើញច្បាស់នូវធម៌តាមពិត កាលបើយថាភូតញ្ញាណទស្សនៈ កើតឡើងហើយ ជាបច្ច័យឲ្យកើត និព្វិទា សេចក្តីនឿយណាយ កាលបើនិព្វិទា កើតឡើងហើយ ជាបច្ច័យឲ្យកើត វិរាគ ការប្រាសចាកតម្រេក កាលបើវិរាគ កើតឡើងហើយ ជាបច្ច័យឲ្យកើត វិមុត្តិ ការរួចផុតស្រឡះចាកកិលេស កាលបើវិមុត្តិ កើតឡើងហើយ ជាបច្ច័យឲ្យកើត វិមុត្តិញ្ញាណទស្សនៈ ប្រាជ្ញាដឹងច្បាស់ឃើញច្បាស់រួចផុតស្រឡះចាកកិលេស ។

កម្មំ សត្តេ វិភជតិ

កម្មរមែងបែងចែកសត្វអោយល្អ រឺ
អាក្រក់ទៅតាមសត្វបានធ្វើ

ធម៌សូត្រសុំសេចក្តីសុខ

✡✡✡ 📖 ✡✡✡

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

(អាកាសាត់ថា ចាក់ ភុមម៉ាត់ថា ទេវ៉ា នាគា មាក់ហិទធិកា)

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។

(ប៉ុញញ៉ាំង នោ អាក់នុមោទាន់តុ ចិរ៉ាំង រ៉ាក់ខាន់តុ សាសាក់ណាំង)

ប្រែថា: *ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវ ព្រះពុទ្ធសាសនា (ឲ្យឋិតថេរ និង ឲ្យរុងរឿង) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

(អាកាសាត់ថា ចាក់ ភុមម៉ាត់ថា ទេវ៉ា នាគា មាក់ហិទធិកា)

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។

(ប៉ុញញ៉ាំង នោ អាក់នុមោទាន់តុ ចិរ៉ាំង រ៉ាក់ខាន់តុ រ៉ាជានោ)

ប្រែថា: *ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះរាជាទាំងឡាយ (ឲ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

(អាកាសាត់ថា ចាក់ ភុមម៉ាត់ថា ទេវា នាគា មាក់ហិទធិកា)

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។

(ប៉ុញញាំង នោ អាក់នុមោទាន់តុ ចិរាំង រាក់ខាន់តុ ញាតាក់យ៉ោ)

__ប្រែថា:__ *ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសាច់ញាតិទាំងឡាយ (ឲ្យចម្រុងចម្រើន និង សុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

(អាកាសាត់ថា ចាក់ ភុមម៉ាត់ថា ទេវា នាគា មាក់ហិទធិកា)

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។

(ប៉ុញញាំង នោ អាក់នុមោទាន់តុ ចិរាំង រាក់ខាន់តុ ប៉ាណិនោ)

__ប្រែថា:__ *ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយ (ឲ្យចម្រុងចម្រើន និង សុខសាន្ត) អស់កាលជាយូរអង្វែងទៅ ។*

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

(អាកាសាត់ថា ចាក់ ភុមម៉ាត់ថា ទេវា នាគា មាក់ហិទធិកា)

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។

(ប៉ុញញាំង នោ អាក់នុមោទាន់តុ ចិរាំង

រាក់ខាន់តុ នោ សាក់ទា)

__ប្រែថា:__ *ទេវតាទាំងឡាយ ដែលឋិតព្ធដ៏អាកាសក្តី ដែលឋិតលើផែនដីក្តីនាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឲ្យបានចម្រុងចម្រើន និង សុខសាន្ត) អស់កាលជាយូរគ្រប់កាលទាំងពួង ។*

កោធោ ទុម្មេធគោចរោ

សេចក្តីក្រោធ ជាគោចររបស់មនុស្សល្ងង់

សុខោ បុញ្ញស្ស ឧច្ចយោ

ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ

បត្តទានគាថា

✡✡✡ 📖 ✡✡✡

យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ

(យា ទេវ៉ាក់តា សន់តិ វិហារ៉ាក់វ៉ាសិណី ថូប៉េ ឃាក់រេ)

ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ

(ពោធិឃាក់រេ តាក់ហឹងៗ តា ធ័មមាក់ទានេនាក់ ភាក់វ៉ាន់តុ)

បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា

(ប៉ូជិតា សោតថឹង កាក់រ៉ោនតេធាក់

វិហារ៉ាក់ម៉ាន់ឌាក់លេ ថេរ៉ា)

ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទានបតី

(ចាក់ម៉ាច់ឈា នាក់វ៉ាក់កាចាក់ ភិកខាក់វ៉ោ សារ៉ាមិកា

ទានាក់ប៉ាក់តី)

ឧបាសកា គាមា ច ទេសា និគ្គមា ច ឥស្សរា

(អ៊ុប៉ាសាក់កា គាមា ចាក់ ទេសា និគគាក់មា

ចាក់ អ៊ិសសាក់រ៉ា)

សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេបិ

(សាបប៉ាណាក់ភូតា សុខិតា ភាក់វ៉ាន់តុ តេ

ជាក់លាពុជា យេប៉ិ)

ច អណ្ឌលសម្ភវា សំសេទជាតា អថោបបាតិកា

(ចាក់ អន់ឌាក់សាំភាក់វា សាំងសេទាក់ជាតា
អាក់ថាក់វ៉ោប៉ាក់ប៉ាតិកា)

និយ្យានិកំ ធម្មចក្កំ បដិច្ច តេ សព្វេបិ

(និយានិកាំង ធ័មមាក់វាក់ុាំង ប៉ាក់ដិចចាក់តេ សាប់ពេពិុ)

ទុក្ខស្ស កពេន្តុ សំខយំ ឋាតុ ចិរំ សតំ

(ទុកខាស់សាក់ កាក់រ៉េនតុ សាំងខាក់យ៉ុាំង ឋាតុ
ចិរ៉ុាំង សាក់តាំង)

ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ

(ធ័មមោ ធ័មមាក់ធាក់រា ចាក់ ប៉ុគគាក់លា សាំងឃោ ហោតុ)

សមគ្គោវ អត្ថាយ ច ហិតាយ ច អម្ហេ

(សាក់មាក់គោវាក់ អាត់ថាយក្ស ចាក់ ហិតាយក្ស ចាក់
អាំមាក់ហេ)

រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ

(រាក់ខាក់តុ សាត់ធ័មមោ សាប់ពេពិុ ធ័មមាក់ចារ៉ិណោ វុឌធឹង)

សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។

(សាំប៉ាប៉ុណើយ៉ាមាក់ ធ័មមារិយ៉ាប់ប៉ាក់វេទិតេ)

<u>ប្រែថា:</u> យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិ-

យេ តហឹ តហឹ ទេវតាទាំងឡាយ ឯណាមានប្រក្រតីនៅក្នុងវត្ត ជាទីនៃសង្ឃ ព្ទដ៍ខឿនព្រះសថូប ព្ទដ៍ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ **តា ធម្មទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គល គឺយើងបូជាហើយ ដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវ សួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសក និង ឧបាសិកាទាំងឡាយ ដែលជាម្ចាស់នៃទានព្រមទាំងអារាមិកជនគឺ ញោមវត្តក្តី **គាមា ច ទេសា និគ្គមា ច ឥស្សរា** ជនទាំងឡាយ ដែលជាអ្នកស្រុកក្តី ជាអ្នក ប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី **សប្បាណភូតា សុខិតា ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឲ្យបាននូវសេចក្តីសុខ **ជលាពុជា យេបិ ច អណ្ឌលសម្ភវា សំសេទជាតា អថវោ- បបាតិកា** មួយវិញទៀតសត្វទាំងឡាយឯណា ដែលជាជលា- ពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈ កំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយ ទាំង

អស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិក-ធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** *សូមឲ្យធម៌របស់សប្បុរសទាំងឡាយ ឋិតនៅអស់កាលយូរអង្វែងទៅ* **ធម្មធរា ច បុគ្គលា** *បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរឋិតនៅ អស់កាលយូរអង្វែងតទៅ)* **សង្ឃោ ហោតុ សមគ្គោច** *សូមព្រះសង្ឃព្រមព្រៀងគ្នា* **អត្ថាយ ច ហិតាយ ច** *ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផល ប្រយោជន៍ផង* **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** *សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្ត ធម៌ទាំងឡាយទាំងអស់ផង* **វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ** *សូមឲ្យយើងទាំងឡាយបានដល់ នូវសេចក្តីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោកសម្តែងហើយ ។*

ខន្តិ បរមំ តបោ តីតិក្ខា

សេចក្តីអត់ធន ជាតបៈធម៌ដ៏ក្រៃលែង

ធម៌សម្រាប់សូត្រឧទ្ទិស

✡✡✡ 📖 ✡✡✡

សូមឲ្យអ្នកទាំងឡាយ សុខសប្បាយទាំងអស់គ្នា
កុំអោយមានរោគា ព្រមទាំងញាតិមិត្តសន្តាន ។
ចូរខំប្រឹងប្រព្រឹត្ត សាងសុចរិតធម៌ឲ្យបាន
សព្វថ្ងៃសាសនាមាន ខំធ្វើទាន សីល ភាវនា ។
កើតមកក្នុងលោកិយ៍ ទាំងប្រុសស្រីមានវាសនា
ខំប្រឹងរៀនធម៌អាទ៍ ទាន់សាសនាព្រះទ្រង់ញាណ ។
ត្បិតយើងមិនដឹងផ្លូវ នឹងដើរទៅកាន់និព្វាន
ជាទីសុខក្សេមក្សាន្ត លះបង់បានចាកមន្ទិល ។
ជាធម៌ប្រពៃពិត វិសេសសិដ្ឋនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហោង ។

តេជៈខ្ញុំសាង

✡✡✡ 🕮 ✡✡✡

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសោភា រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ឋានថ្លៃថ្លា ។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ខ្ញុំសូមសច្ចា កើតជាតិណាៗ សូមឲ្យបានសុខ
សូមមានបញ្ញា ភ្លឺថ្លាមុះមុត រួចផុតពីទុក្ខ
ដល់និព្វានហោង ។

អនុស្សតិ ១០ យ៉ាង

✡✡✡ 📖 ✡✡✡

១. ពុទ្ធានុស្សតិ *(ពុទធានុសសាក់តិ) រឭកដល់គុណព្រះពុទ្ធ*

២. ធម្មានុស្សតិ *(ធ័មមានុសសាក់តិ) រឭកដល់គុណព្រះធម៌*

៣. សង្ឃានុស្សតិ *(សាំងឃានុសសាក់តិ) រឭកដល់គុណព្រះសង្ឃ*

៤. សីលានុស្សតិ *(សីឡានុសសាក់តិ) រឭកដល់សីលរបស់ខ្លួន*

៥. ចាគានុស្សតិ *(ចាគានុសសាក់តិ) រឭកដល់ទានដែលខ្លួនបរិច្ចាគហើយ*

៦. ទេវតានុស្សតិ *(ទេវ៉ានុសសាក់តិ) រឭកដល់គុណព្រះធម៌ធ្វើឲ្យកើតជាទេវតា*

៧. មរណានុស្សតិ *(មាក់រាក់ណានុសសាក់តិ) រឭកដល់សេចក្តីស្លាប់*

៨. កាយគតានុស្សតិ *(កាយក្សគាក់តានុសសាក់តិ) រឭកដល់កាយឲ្យឃើញថាមិនស្អាតមិនល្អ*

៩. អានាបានុស្សតិ *(អាណាប៉ានុសសាក់តិ) រឭកដល់ខ្យល់ដកដង្ហើមចេញចូល*

១០. ឧបសមានុស្សតិ *(អ៊ុប៉ាក់សាក់ម៉ានុសសាក់តិ) រឭកដល់ធម៌ជាទីស្ងប់រម្ងាប់ គឺព្រះនិព្វាន ។*

ធម៌សម្រាប់ប្រោះចទឹកស្តោធក់

✡✡✡ 📖 ✡✡✡

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា

(អ៊ិមិណា ប៉ុញញាក់កាំមេនាក់ អ៊ុប៉ាច់ឈាយា គុណុតតាក់រ៉ា)

អាចរិយូបការា ច មាតាបិតា (ច ញាតិកា)

(អាចាក់រិយូប៉ាក់ការ៉ា ចាក់ មាតាប៉ិតា (ចាក់ ញាតិកា))

បិយាមមំ សុរិយោ ចន្ទិមា រាជា គុណវន្តា

(ប៉ិយ៉ាមាក់មាំង សុរិយ៉ោ ចាន់ទិមា រាជា គុណាក់វាន់តា)

នរាបិ ច ព្រហ្មា មារា ច ឥន្ទ្រា ច លោកបាលា

(នាក់រាប៉ិ ចាក់ ប្រាំមា មារា ចាក់ អ៊ិនទ្រា ចាក់ លោកាក់ប៉ាឡា)

ច ទេវតា យមោ មិត្តា មនុស្សា ច មជ្ឈត្តា

(ចាក់ ទេវាក់តាយក្សមោ មិតតា មាក់នុសសា
ចាក់ម៉ាច់ឈាត់តា)

វេរិកាបិ ច សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ

(វេរិកាប៉ិ ចាក់ សាប់ពេ សាត់តា សុខី ហោនតុ ប៉ុញញ៉ានិ)

បកតានិ មេ សុខញ្ចា តិវិធំ ទេន្តុ ខិប្បំ

(ប៉ាក់កាក់តានិ មេ សុខាញ់ចាក់ តិវិធាំង ទេនតុ ខិបប៉ាំង)

បាបេថ វោមតំ ។ *(ប៉ាប៉េថាក់ វោមាក់តាំង) ។*

ប្រែថា: ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់អាចារ្យទាំងឡាយមានឧបការៈមាតាបិតាជាទីស្រឡាញ់នៃខ្ញុំ ព្រះអាទិត្យ ព្រះចន្ទ រាជការ នរជនអ្នកមានគុណទាំងឡាយ ព្រះព្រហ្ម មារាធិរាជ ព្រះឥន្ទទាំងឡាយ លោកបាលមហារាជ និងទេវតាទាំងឡាយ ព្រះយមរាជ និងមនុស្សទាំងឡាយ ជាមិត្តនឹងគ្នាក្តី មានចិត្តជាកណ្តាលក្តី មានពៀរជាមួយគ្នាក្តី (រូបរួមសេចក្តីថា) សូមឲ្យសព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យទាំងឡាយ ដែលខ្ញុំបានសាងសន្សំហើយ ចូរឲ្យនូវសេចក្តីសុខទាំង ៣ ប្រការ សូមឲ្យអ្នកទាំងឡាយបានដល់នូវអមតមហានិព្វាន អោយបានឆាប់រួសរាន់ទាន់សេចក្តីប្រាថ្នាហោង ។

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច

(អ៊ិមិណា ប៉ុញញ្ញាក់កាំមេនាក់ អ៊ិមិណា អ៊ុទទិសេនាក់ ចាក់)

ខិប្បាហំ សុលភេចេវ តណ្ហុប្បទាន~

(ខិបប៉ាហាំង សុឡាក់ភេចេវាក់តន់នាក់ហុបប៉ាទានាក់)

ឆេទនំ យេ សន្តានេ ហីនាធម្មា យាវ និព្វានតោ

(ឆេទាក់ណាំង យេ សន់តានេ ហីណាធ័មមា យាវ៉ាក់ នីពពានាក់តោ)

មមំ នសុ្សន្តុ សព្វធាយេវ យត្ថ ជាតោ

(មាក់មាំង នាស់សន់តុ សាប់ពាក់ទាយេវាក់ យ៉ាត់ថាក់ជាតោ)

ភវាភវេ ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ

(ភាក់វាភាក់វេ អ៊ុជុចិត្តតោ សាក់តិបប៉ាញ់ញ៉ោ សាល់ឡេខោ)

វីរិយោម្ហិ វា មារា លភន្តុ នោ ភាសំ ភាតុញ្ច

(វិរិយោមហិ វា មារា លាក់ភាន់តុ នោ កាសាំង កាតុញចាក់)

វីរិយេ សុមេ ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ

(វិរិយេសុមេ ពុទ្ធោ ទីប៉ាក់វាក់រោ នាថោ ធ័មមោនាថោ)

វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ

(វាក់រុតតាក់ម៉ោនាថោ ប៉ាច់ចេកាក់ពុទ្ធោ ចាក់ សាំងឃោ)

នាថោត្តរោ មមំ តេ សោត្តមានុភាវេន

(នាថោតតាក់រ៉ោ មាក់មាំង តេ សោតតាក់ម៉ានុភាវេនាក់)

មារោ ភាសំ លភន្តុ មា ។

(មារោ កាសាំង លាក់ភាន់តុ មា)

__ប្រែថា:__ ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង សូមឲ្យខ្ញុំបានដោយងាយ យ៉ាងរួសរាន់ទាន់ចិត្ត នូវមគ្គផលជាគ្រឿងផ្តាច់បង់នូវតណ្ហា និង ឧបាទានធម៌ទាំងឡាយណាជាធម៌ថោក

ទាប គឺជាអកុសលធម៌នៅក្នុងសន្តានចិត្តខ្ញុំ សូមឲ្យ (ហើនធម៌ជាធម៌អកុសលទាំងនោះ) វិនាសបាត់រៀងរាល់កាលទៅរហូតដល់ខ្ញុំបានសម្រេចព្រះនិព្វាន (ក្នុងបច្ឆិមជាតិ) (បើ) ខ្ញុំអន្ទោលទៅចាប់កំណើតក្នុងភពតូច និង ភពធំណាៗ សូមឲ្យខ្ញុំជាបុគ្គលមានចិត្តត្រង់មានសតិ និង បញ្ញា មានចិត្តស្អាតផូរផង់ ទាំងសូមអោយព្យាយាមផង (ក្នុងភពនោះៗ) មារទាំងឡាយចូរកុំបាននូវឱកាសដើម្បីឲ្យខូចព្យាយាមខ្ញុំ ព្រះពុទ្ធដូចជាប្រទីប ឬកោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាទីពឹងដ៏ប្រសើរខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធ ក៏ជាទីពឹងនៃខ្ញុំផងដែរ ព្រះសង្ឃក៏ជាទីពឹងនៃខ្ញុំផងដែរ ដោយឧត្តមមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និង ព្រះសង្ឃនោះ មារចូរកុំបាននូវឱកាសចូលមកជ្រៀតជ្រែកឡើយ។

ខន្តិ ធីរស្សលង្ការោ

សេចក្តីអត់ធន ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ

ខមាបនគាថា

✡✡✡ 🕮 ✡✡✡

យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា

(យេកេចិ ខុទទាក់កា ប៉ាណា មាក់ហាន់តាប៉ិ មាក់យា)

ហតា យេ បាណកេ បមាទេន កាយវាចាមនេហិ

(ហាក់តា យេ ប៉ាណាក់កេ ប៉ាក់ម៉ាទេនាក់

កាយក្បវាចាមាក់នេហិ)

វា បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ

(វា ប៉ុញញាំង មេ អាក់នុមោទន់តុ គាន់ហាន់តុ)

ផលមុត្តមំ វេរិនោ ចេ បមុញ្ចន្តុ

(ផាក់ឡាក់មុតតាក់មាំង វេរិនោ ចេ ប៉ាក់ម៉ុញចាន់តុ)

សព្វទោសំ ខមន្តុ មេ។

(សាប់ពាក់ទោសាំង ខាក់ម៉ន់តុ មេ) ។

<u>ប្រែថា:</u> សត្វទាំងឡាយណាមួយ ទោះបីតូចក្តីធំក្តី ដែលខ្ញុំបាន បៀតបៀនហើយ មួយទៀតសត្វទាំងឡាយពួកខ្លះ (ដែលខ្ញុំបាន ធ្វើទុក្ខបុកម្នេញហើយ) ព្រោះសេចក្តីប្រមាទភ្លាំងភ្លាត់ ដោយ កាយវាចាចិត្ត (សត្វទាំងឡាយនោះ) ចូរអនុមោទនានូវបុណ្យ

របស់ខ្ញុំចុះ ចូរទទួលយកនូវផលបុណ្យដ៏ឧត្តមចុះ បើ (សត្វទាំងឡាយឯណា) មានពៀរនឹងគ្នា (សត្វទាំងឡាយ) នោះចូររួចរំដោះចាកពៀរនោះទៅ " សូមសត្វទាំងឡាយអត់ទោសទាំងពួងដល់ខ្ញុំផង " ។

បត្តទានគាថា

✡✡✡ 📖 ✡✡✡

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម

(យុាំង កិញ្ចចិ កុសាក់ឡាក់កាំម៉ាំង កាត់តាប់ពាំង កិរិយុាំង មាក់មាក់)

កាយេន វាចា មនសា តិទសេ សុគតំ កតំ យេ

(កាយេនាក់ វាចា មាក់នាក់សា តិទាក់សេ សុគាក់តាំង កាក់តាំង យេ)

សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ

(សាត់តា សាញ់ញិណោ អាត់ថិ យេ ចាក់ សាត់តា អាក់សាញ់ញិណោ)

កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ

(កាក់តាំង ប៉ុញញាក់ផាក់ឡាំង ម៉ៃហាំង សាប់ពេ ភាគី ភាក់វាន់តុ តេ)

យេ តំ កតំ សុចិទិតំ ទិន្នំ បុញ្ញផលំ មយា

(យេ តាំង កាក់តាំង សុវិទិតាំង ទិនណាំង

ប៉ុញញាក់ផាក់ឡាំង មាក់យា)

យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ

(យេ ចាក់ តាត់ថាក់ នាក់ ជាណាន់តិ ទេវា គាន់ត្វា

និវេទាក់យុង សាប់ពេ)

លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ

(លោកាំហិ យេ សាត់តា ជីវាន់តាហារាក់ហេតុកា

មាក់នុញញាំង)

ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

(ភោជាក់ណាំង សាប់ពេ លាក់ភាន់តុ មាក់មាក់ ចេតាក់សាតិ)

<u>**ប្រែថា:**</u> **យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** *អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ* **កាយេន វាចា មនសា** *ដោយទ្វារទាំង៣ គឺកាយ វាចា ចិត្ត* **តិទសេ សុគតំ កតំ** *អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យកើតក្នុងឋានត្រៃត្រិង្សស្ងួគ៌បាន* **យេ សត្តា សញ្ញិនោ អត្ថិ** *សត្វទាំងឡាយឯណា គឺមនុស្ស ឬ ទេវតា ឬ ព្រហ្ម ដែលជាសត្វមានសញ្ញាក្តី* **យេ ច សត្តា អសញ្ញិនោ** *សត្វទាំងឡាយឯណាជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី* **កតំ បុញ្ញផលំ មយ្ហំ ស**

សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះចូរឲ្យបាន នូវចំណែកផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបាន ដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផល នៃបុណ្យដែលខ្ញុំបានឧទ្ទិសឲ្យទៅនេះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះឲ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យហើយឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្តដែលសម្រេចដោយ បុញ្ញរិទ្ធិតាមចិត្តនៃខ្ញុំដែលឧទ្ទិសផ្សាយទៅឲ្យនេះចុះ ។

យំកញ្ចិប្រែជាពាក្យកាព្យ

✡✡✡ 📖 ✡✡✡

កម្មជាកុសលឯណា   ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង   ដោយទ្វារកាយ វាចា ចិត្ត ។
កុសលទាំងអស់នោះ   អាចជួយដោះជួយបង្ខិត
នាំសត្វឲ្យជាប់ចិត្ត   ស្ថិតនៅនាស្ថានឧត្តម ។
សត្វណាមានសញ្ញា   មនុស្សទេវតាឬឥន្ទព្រហ្ម
ដែលមានសត្វតូចធំ   ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ   ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា   ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា   ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេវតាទៅប្តឹង   ឲ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯនុះ   ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា   វត្ថុជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល   ឲ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ   បន្ទន់កាយទទួលយក ។

សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឲ្យបានកុំខានឡើយ ។

ធម៌ឧទ្ទិសផល

✡✡✡ 📖 ✡✡✡

ទានសីលដែលខ្ញុំបានធ្វើហើយ ព្រះគុណអើយខ្ញុំសទ្ធា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូន និង ជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានអោយបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
ដែលមានចិត្តមេត្តា នាំផលាទាំងអស់នេះ ។
ទៅជូនអោយខ្ញុំផង ដូចបំណងកុំបីធ្វេស

កូនចៅនៅឯណោះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយផលទាន សូមអោយបាននៅសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ។

ធម៌ឧទ្ទិសសង្ខេប

✡✡✡ 📖 ✡✡✡

ទានសីលយើងទាំងឡាយ សូមផ្សព្វផ្សាយដល់ញាតិមិត្ត
ទៅកាន់ទីឆ្ងាយជិត មានវិបត្តិយ៉ាងណាក្តី ។
សូមឲ្យរួចរដោះ ចាកទុក្ខទោសគ្រោះចង្រៃ
បានសុខរៀងរាល់ថ្ងៃ ដរាបដល់និព្វានហោង ។

អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំ រក្ខតិ
អ្នកប្រាជ្ញតែងរក្សាការមិនប្រមាទ
ដូចជាការរក្សានូវទ្រព្យដ៏ប្រសើរ

ផ្សាយមេត្តាចំពោះទិសទាំង ១០

✡✡✡ 📖 ✡✡✡

<u>**ប្រែថា:**</u>

១. សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសបូព៌ សូមកុំឲ្យ មានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។*

២. សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសអាគ្នេយ៍ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។*

៣. សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសទក្សិណ សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។*

៤. សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសនិរតី សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។*

៥. សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសបស្ចឹម សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។*

៦. សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសពាយ័ព្យ សូម*

កុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

៧. សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសឧត្តរ សូមកុំឲ្យ មានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

៨. សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសឦសាន សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

៩. សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសខាងក្រោម សូម កុំឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

១០. សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង " ដែលស្ថិតនៅ " ក្នុងទិសខាងលើ សូមកុំ ឲ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា

(សាប់ពេ សាត់តា អាក់វេរា ហោនតុ សុខិតា ហោនតុ និទទុក្ខខា)

ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា

(ហោនតុ អាប់ព្យាប៉ាច់ឈា ហោនតុ អាក់នីឃា ហោនតុ ទីឃាយុកា)

ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី

(ហោនតុ អាក់រោគា ហោនតុ សាំប៉ាត់តីហិ

សាក់មិជឆន់តុ សុខី)

អត្តានំ បរិហរន្តុ ។ (*អាត់តាណាំង ប៉ាក់រិហាក់រ៉ន់តុ*)

សូមឲ្យសត្វទាំងឡាយទាំងពួងកុំមានពៀរនឹងគ្នា សូមឲ្យបាននូវ សេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឲ្យជាសុខតរៀងទៅ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា

(ទុកខាប់ប៉ាត់តា ចាក់ និតទុកខា ភាក់យ៉ាប់ប៉ាត់តា

ចាក់ និបភាក់យា)

សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

(សោកាប់ប៉ាត់តា ចាក់ និសសោកា ហោនតុ

សាប់ពេប៉ិ ប៉ាណិណោ)

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

សុភមង្គលកថា

✡✡✡ 📖 ✡✡✡

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា

(ហោតុ សាប់ពាំង សុមាំងគាក់លាំង រាក់ខានតុ សាប់ពាក់ទេវាក់តា)

សព្វពុទ្ធានុភាវេន សព្វធម្មានុភាវេន

(សាប់ពាក់ពុធធានុភាវេនាក់ សាប់ពាក់ធ័មមានុភាវេនាក់)

សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ ។

(សាប់ពាក់សាំងឃានុភាវេនាក់ សោតថិ ហោតុ និរ៉ន់តាក់រ៉ាំង)

<u>ប្រែថា:</u> ហោតុ សព្វំ សុមង្គលំ *សុមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ* **រក្ខន្តុ សព្វទេវតា** *ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ* **សព្វពុទ្ធានុភាវេន** *ដោយអនុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ* **សព្វធម្មានុភាវេន** *ដោយអានុភាពនៃព្រះធម៌ទាំងពួង* **សព្វសង្ឃានុភាវេន** *ដោយអនុភាពនៃព្រះសង្ឃទាំងពួង* **សោត្ថិ ហោតុ និរន្តរំ** *សូមសិរីសួស្តីចូរមានដល់ខ្ញុំឲ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។*

បារមីធម៌ ៣០ យ៉ាង

✡✡✡ 📖 ✡✡✡

១. ឥតិបិ ទានបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ ទានាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ ទានឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ ទានាក់អ៊ុប៉ាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ ទានបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ ទានាក់ប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

២. ឥតិបិ សីលបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ សីលាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ សីលឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ សីលាក់អ៊ុប៉ាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ សីលបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ សីលាក់ប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

៣. ឥតិបិ នេក្ខម្មបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ នេកខាន់មាក់ប៉ារាក់ម៉ី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ នេក្ខម្មឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៊ិ នេកខាន់មាក់អ៊ុប៉ាក់ប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ នេក្ខមបរមត្ថបារមី សម្បន្នោ សោតគទា ។

(អ៊ិតិប៊ិ នេកខាន់មាក់ប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

៤. ឥតិបិ បញ្ញាបារមី សម្បន្នោ សោតគទា

(អ៊ិតិប៊ិ ប៉ាញ់ញ៉ាប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ បញ្ញាឧបបារមី សម្បន្នោ សោតគទា

(អ៊ិតិប៊ិ ប៉ាញ់ញ៉ាអ៊ុប៉ាក់ប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ បញ្ញាបរមត្ថបារមី សម្បន្នោ សោតគទា ។

(អ៊ិតិប៊ិ ប៉ាញ់ញ៉ាប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

៥. ឥតិបិ វីរិយបារមី សម្បន្នោ សោតគទា

(អ៊ិតិប៊ិ វីរិយក្យប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ វីរិយឧបបារមី សម្បន្នោ សោតគទា

(អ៊ិតិប៊ិ វីរិយក្យអ៊ុប៉ាក់ប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ វីរិយបរមត្ថបារមី សម្បន្នោ សោតគទា ។

(អ៊ិតិប៊ិ វីរិយក្យប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់ម៉ិ សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

៦. ឥតិបិ ខន្តិបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ ខាន់តិប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ ខន្តិឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ ខាន់តិអ៊ុប៉ាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ ខន្តិបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ ខាន់តិប៉ាក់រ៉ាក់ម៉ាត់ថាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

៧. ឥតិបិ សច្ចបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ សាច់ចាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ សច្ចឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ សាច់ចាក់អ៊ុប៉ាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ សច្ចបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ សាច់ចាក់ប៉ាក់រ៉ាក់ម៉ាត់ថាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

៨. ឥតិបិ អធិដ្ឋានបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ អាក់ធិតឋានាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ អធិដ្ឋានឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ អាក់ធិតឋានាក់អ៊ុប៉ាក់ប៉ារ៉ាក់មី សាំប៉ាន់ណោ សោភាក់គាក់វ៉ា)

ឥតិបិ អធិដ្ឋានបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ អាក់ធិតឋានាក់ប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

៩. ឥតិបិ មេត្តាបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ មេតតាប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

ឥតិបិ មេត្តាឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ មេតតាអ៊ុប៉ាក់ប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

ឥតិបិ មេត្តាបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ មេតតាប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

១០. ឥតិបិ ឧបេក្ខាបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ អ៊ុបេកខាប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

ឥតិបិ ឧបេក្ខាឧបបារមី សម្បន្នោ សោភគវា

(អ៊ិតិប៉ិ អ៊ុបេកខាអ៊ុប៉ាក់ប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

ឥតិបិ ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោភគវា ។

(អ៊ិតិប៉ិ អ៊ុបេកខាប៉ាក់រាក់ម៉ាត់ថាក់ប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វា)

ឥតិបិ សមតឹសបារមី សម្បន្នោ សោភគវាតិ ។

(អ៊ិតិប៉ិ សាក់មាក់តិងសាក់ប៉ារាក់មី សាំប៉ាន់ណោ សោភាក់គាក់វាតិ)

កុសលកម្មបថ ១០ យ៉ាង

✡✡✡ 🕮 ✡✡✡

<u>កាយកម្ម ៣ យ៉ាង</u>

១. បាណាតិបាតា វេរមណី *(ប៉ាណាតិបាតា វេរ៉ាក់មាក់នី) ចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។*

២. អទិន្នាទានា វេរមណី *(អាក់ទិននាទានា វេរ៉ាក់មាក់នី) ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ។*

៣. កាមេសុមិច្ឆាចារា វេរមណី *(កាម៉េសុមិចឆាចារ៉ា វេរ៉ាក់មាក់នី) ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។*

<u>វចីកម្ម ៤ យ៉ាង</u>

១. មុសាវាទា វេរមណី *(មុសាវ៉ាទា វេរ៉ាក់មាក់នី) ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។*

២. បិសុណាវាចា វេរមណី *(ប៉ិសុណាវ៉ាចា វេរ៉ាក់មាក់នី) ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។*

៣. ផរុសវាចា វេរមណី (ផាក់រុសាក់វាចា វេរាក់មាក់នី) ចេតនាជាហេតុវៀរ ចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

៤. សម្ផប្បលាបា វេរមណី (សាំផាប់ប៉ាក់ឡាប៉ា វេរាក់មាក់នី) ចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

<u>មនោកម្ម ៣ យ៉ាង</u>

១. អនភិជ្ឈា (អាក់នាក់ភិចឈា) មិនមានចិត្តគិតសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។

២. អព្យាបាទោ (អាក់ព្យាប៉ាទោ) មិនមានចិត្តចងគំនុំគំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ ។

៣.សម្មាទិដ្ឋិ (សាំម៉ាទិដថិ) គំនិតយល់ឃើញត្រូវពិតហើយ ប្រកាន់ឡើងថាពិតជាត្រូវមែន ។

អ្នកណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលមកហើយនេះ អ្នកនោះនឹងមានសេចក្តី ចំរើនក្នុងលោកទាំង ២ គឺក្នុងលោកនេះ និង បរលោកនាយជាប្រាកដ ។

អកុសលកម្មបថ ១០ យ៉ាង

-❖,

កាយកម្ម ៣ យ៉ាង

១. **បាណាតិបាតា** (ប៉ាណាតិបាតា) កិរិយាសម្លាប់សត្វ ដោយកាយរបស់ខ្លួន ឬ ប្រើគេសម្លាប់ដោយវាចារ ។

២. **អទិន្នាទានា** (អាក់ទិននាទានា) កិរិយាលួចលាក់ ឆក់ ដណ្ដើមទ្រព្យគេដោយកាយរបស់ខ្លួន ឬ ប្រើគេឲ្យលួចលាក់ឆក់ ដណ្ដើមដោយវាចារ ។

៣. **កាមេសុមិច្ឆាចារា** (កាម៉េសុមិចឆាចារ៉ា) កិរិយាប្រព្រឹត្ត ខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវននឹងស្ត្រី ដែលមាន គេហួងហែងរក្សា ។

វចីកម្ម ៤ យ៉ាង

១. **មុសាវាទា** (មុសាវាទា) កិរិយាពោលនូវពាក្យកុហក។

២. **បិសុណាវាចា** (ប៉ិសុណាវាចា) កិរិយាពោលនូវពាក្យ ញុះញង់ ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

៣. **ផរុសវាចា** (ផាក់រុសាក់វាចា) កិរិយាពោលនូវពាក្យ អាក្រក់ មានពាក្យទ្រគោះ ប្រោះប្រោក ជេរប្រទេចអ្នកដទៃ ជា

ដើម ។

៤. សម្ផប្បលាបា (សាំផាប់ប៉ាក់ឡាប៉ា) កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

<u>មនោកម្ម ៣ យ៉ាង</u>

១. អភិជ្ឈា (អាក់ភិចឈា) ចិត្តគិតសំឡឹង រំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។

២. ព្យាបាទោ (ព្យាប៉ាទោ) ចិត្តចងគំនុំគំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ ។

៣. មិច្ឆាទិដ្ឋិ (មិចឆាទិដថិ) គំនិតយល់ឃើញថាខុសហើយ ប្រកាន់ឡើងថាជាត្រូវ ។

(ចប់ដោយសង្ខេបតែប៉ុណ្ណេះ)